# មាតិកា

ព្រឹត្តិបត្រព័ត៌មានបេឡាជាតិរបបសន្តិសុខសង្គម


១- រចនាសម្ព័ន្ធបេឡាជាតិរបបសន្តិសុខសង្គម.....១
២- កិច្ចប្រជុំស្ដីពីវឌ្ឍនភាពការងារឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ២០១៥ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ.....២
៣- បេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១៤ និងលើកទិសដៅសម្រាប់ឆ្នាំ២០១៥.....៣
៤- ដំណើរទស្សនកិច្ចសិក្សាដើម្បីស្វែងយល់អំពីប្រព័ន្ធសោធន នៅប្រទេសជប៉ុន.....៥
៥- កិច្ចប្រជុំផ្សព្វផ្សាយអប់រំ ស្ដីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅរោងចក្រ ELITE (CAMBODIA) CO.,LTD ខេត្តស្វាយរៀង.....៦
៦- បេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំ ដល់អ្នកបើកបរយានយន្ត ស្ដីពីច្បាប់ចរាចរណ៍ផ្លូវគោកថ្មី នៅខេត្តកំពង់ឆ្នាំង.....៧
៧- កិច្ចប្រជុំ ស្ដីពីការអនុវត្តគោលនយោបាយថ្មីៗ និងពង្រឹងសេវានៃការផ្ដល់តាវកាលិកហានិភ័យការងារ.....៨
៨- ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក ចុះផ្សព្វផ្សាយអប់រំ ដល់អ្នកបើកបរ អំពីការគោរពច្បាប់ចរាចរណ៍ នៅរោងចក្រ SIXPLUS INDUSTRY CO.,Ltd ខេត្តកណ្ដាល.....៩
៩- កិច្ចប្រជុំផ្សព្វផ្សាយអប់រំ ស្ដីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅរោងចក្រ A & J (Cambodia) Co.,Ltd ខេត្តស្វាយរៀង.....១០
១០- ការកំណត់ចំនួនរោងចក្រសម្រាប់ប្រជុំផ្សព្វផ្សាយអប់រំឆ្នាំ២០១៥ អំពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ លក្ខខណ្ឌការងារ អត្ថប្រយោជន៍បេឡាជាតិរបបសន្តិសុខសង្គម និងសុវត្ថិភាពលើមធ្យោបាយដឹកជញ្ជូនកម្មករ.....១១
១១- ដំណើរឆ្ពោះទៅមុខរបស់ស្ត្រីកម្ពុជាក្រោយសន្និសីទស្ត្រីពិភពលោក ទិវានារីអន្តរជាតិ.....១២
១២- កិច្ចប្រជុំផ្សព្វផ្សាយ ស្ដីពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ លក្ខខណ្ឌការងារ អត្ថប្រយោជន៍របបសន្តិសុខសង្គម នៅខេត្តព្រះសីហនុ.....១៣
១៣- ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ ទ.ស.ប.ក ចុះអង្កេតករណីសន្លប់ នៅរោងចក្រ GRAND EAST FOOTWEAR INT'L CORP.....១៤
១៤- បេឡាជាតិរបបសន្តិរបបសន្តិសុខសង្គម (ប.ស.ស) ប្រជុំផ្សព្វផ្សាយ ស្ដីពីគោលនយោបាយថ្មីៗ និងពង្រឹងការផ្ដល់សេវាតាវកាលិក នៅខេត្តឧត្តរមានជ័យ.....១៥
១៥- ឆ្លងចរន្តអគ្គិសនីចេញពីម៉ាស៊ីនកំដៅស្បែកជើង បង្កឱ្យកម្មករនិយោជិត ៤៨នាក់សន្លប់ នៅរោងចក្រ LONG LEAD ខេត្តកំពង់ឆ្នាំង.....១៦
១៦- ការចុះអង្កេតករណីកម្មករនិយោជិតសន្លប់ នៅរោងចក្រ យូលី អ៊ិនធើរណេសិណល (ខេមបូឌា) ហ្គាមិន ខេត្តស្វាយរៀង.....១៧
១៧- មនុស្ស ៨នាក់រងរបួស ដោយគ្រោះថ្នាក់ចរាចរណ៍ដែលបង្កឡើង រវាងម៉ូតូបុកជាមួយម៉ូតូ នៅខេត្តកំពង់ឆ្នាំង.....១៨
១៨- កម្មការិនី ៣នាក់សន្លប់ បង្កធ្វើឱ្យកម្មការិនីផ្សេងទៀតមានការភិតភ័យសន្លប់តៗគ្នារហូតដល់៦៩នាក់.....១៩
១៩- ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក ចុះផ្សព្វផ្សាយអប់រំអំពីច្បាប់ ស្ដីពីចរាចរណ៍ផ្លូវគោក នៅខេត្តកណ្ដាល.....២០
២០- ខិត្តប័ណ្ណផ្សព្វផ្សាយ.....២១
២១- សារសំខាន់នៃការចុះសំបុត្រអាពាហ៍ពិពាហ៍របស់កម្មករនិយោជិត.....២២
២២- ដំណោះស្រាយដើម្បីបញ្ចៀស និងទប់ស្កាត់ពេលកើតឡើងនូវឧប្បទវហេតុក្នុងក្លែងធ្វើការ.....២៣
២៣- អ្នកដើរផ្ញើជីវិត លើអ្នកបើកបរ.....២៤
២៤- ច្បាប់ទូន្មានសម្រាប់ជនប្រុសស្រី.....២៥
២៥- ផ្លែគីវីផ្ដល់ប្រយោជន៍ច្រើនចំពោះរាងកាយ.....២៦
២៦- ទស្សនគួរពិចារណា.....២៧
២៧- ក្រុមប្រចាំការ HOTLINE 24 ម៉ោង.....២៨
២៨- អាសយដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង សាខា ប.ស.ស តាមបណ្ដារាជធានី-ខេត្ត.....២៩
២៩- លេខទូរស័ព្ទទំនាក់ទំនងតាមមន្ទីរពេទ្យដែលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.....៣១






## រចនាសម្ព័ន្ធព្រឹត្តិបត្រ ប.ស.ស

លោក អ៊ុក សមវិទ្យា នាយក ប.ស.ស

ចាងហ្វាង លោក ជាវ ប៊ុនរិទ្ធ

និពន្ធនាយក លោក ឌួង ច័ន្ទតារា

និពន្ធនាយករង លោក ចាយ សំណាង

លោក ស្រី សៅ

លេខានិពន្ធ លោកស្រី សុខ សូរ្យរស្មី

កញ្ញា យ៉ែម ចន្ធូ

ផ្នែកកុំព្យូទ័រ លោក យុន វិចិត្រ

លោក ពៅ សុវណ្ណារ៉ា

# រចនាសម្ព័ន្ធបេឡាជាតិរបបសន្តិសុខសង្គម



# កិច្ចប្រជុំស្តីពីវឌ្ឍនភាពការងារឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ២០១៥ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

កាលពីព្រឹកថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៥ នៅទីស្តីការក្រសួង មានបើកកិច្ចប្រជុំបូកសរុបការងារប្រចាំឆ្នាំ ស្តីពីវឌ្ឍនភាពការងារ ឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ២០១៥ នៃការអនុវត្តផែនការ យុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្នាក់ដឹកនាំក្រសួង, និងមន្ត្រី ក្រោមឱវាទជាច្រើនរូបទៀត។



ឯកឧត្តមរដ្ឋមន្ត្រី អ៊ិត សំហេង អញ្ជើញជាអធិបតីក្នុងពិធីប្រជុំ

កិច្ចប្រជុំបានរៀបចំឡើងក្នុងគោលបំណង ដើម្បីពិនិត្យតាម ដានរាល់សកម្មភាពការងាររបស់ក្រសួងផ្ទាល់ ក៏ដូចជាការងារ របស់អង្គភាពចំណុះឱ្យក្រសួងតាមផ្នែកនីមួយៗ ដោយធ្វើការវាស់ ពីកម្រិតនៃសន្ទុះការងារ ឱ្យស្របទៅនឹងផែនការសកម្មភាពដែល បានកំណត់ តាមផ្នែកពាក់ព័ន្ធ និងកំណត់គោលដៅជាក់លាក់ ដោយធ្វើការប្រៀបធៀប និងធ្វើការលំអបន្ថែមសម្រាប់ឆ្នាំបន្ទាប់។

ម្យ៉ាងវិញទៀតក៏ទាមទារឱ្យមានការសិក្សាស្រាវជ្រាវរកឱ្យ ឃើញនូវចំណុចអសកម្ម ឬក៏ការរាំងស្ទះ (ចំណុចខ្លាំង និងចំណុច ខ្សោយ) ដើម្បីពន្លឿនសេវាសាធារណៈ ដោះស្រាយការប្រឈម ឱ្យបានទាន់ពេលវេលា ដើម្បីបំពេញនូវសេចក្តីត្រូវការរបស់ប្រជា ពលរដ្ឋ ក៏ដូចជាកម្មករនិយោជិតផង។



សុន្ទរៈកថារបស់ ឯកឧត្តមរដ្ឋមន្ត្រី ថ្លែងក្នុងកិច្ចប្រជុំ

ក្នុងឱកាសនោះ លោក អ៊ុក សមវិទ្យា នាយកប.ស.ស បាន ជម្រាបជូនអង្គប្រជុំនូវរបាយការណ៍ ដែលទាក់ទងទៅនឹងការ អនុវត្តការងាររបស់ខ្លួនក្នុងឆ្នាំ២០១៤ កន្លងមកទទួលបានលទ្ធ ផលល្អគួរជាទីមោទនៈ។ ទន្ទឹមនឹងនោះក៏យើងត្រូវកំណត់ទិន្នន័យ ឬតួលេខឱ្យបានជាក់លាក់ ដើម្បីធ្វើការសន្និដ្ឋានរួមវែកញែកទាញ រកហេតុផលនានា ធ្វើការវាស់ស្ទង់ និងវាយតម្លៃទៅលើលទ្ធផល



ថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសិក្ខាកាមចូលរួមក្នុងកិច្ចប្រជុំ

ដែលសម្រេចបានក្នុង ការបង្កើតឱ្យចេញជាគោលការណ៍ រួម សម្រាប់ធ្វើការទប់ស្កាត់ និងបង្ការនូវផ្នែកទាំងពីរនេះ ដែលជា ផ្នែកមួយមានហេតុផលរួមគ្នា និងត្រូវបានចាត់ទុកថា ជាគ្រោះ ថ្នាក់ការងារ ដែលតម្រូវឱ្យធ្វើការទប់ស្កាត់ និងបង្ការហានិភ័យ ទាំងនេះឱ្យនៅកម្រិតទាបបំផុត និងកំណត់ទិសដៅឱ្យបានច្បាស់ ដើម្បីអនុវត្តបន្តទទួលបានលទ្ធផលល្អបន្ថែមទៀត។

ចុងក្រោយ ឯកឧត្តមរដ្ឋមន្ត្រី បានកោតសរសើរនូវសមិទ្ធផល ការងារដែលសម្រេចបានកន្លងមកមានភាពរីកចំរើន និងមានការ កើនឡើងគួរឱ្យកត់សម្គាល់នូវគ្រប់ហេដ្ឋារចនាសម្ព័ន្ធរបស់ក្រសួង ដែលបានធ្វើការកែទម្រង់រដ្ឋបាលសាធារណៈ ដោយអនុវត្តបាន ស៊ីជម្រៅស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់ រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ក៏ដូចជាផែនការយុទ្ធ សាស្ត្ររបស់ក្រសួង៕

# បេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារ សម្រេចបានឆ្នាំ២០១៤ និងលើកទិសដៅសម្រាប់ឆ្នាំ២០១៥

បេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១៤ និងលើកទិសដៅសម្រាប់ឆ្នាំ២០១៥ នៅសណ្ឋាគារភ្នំពេញ កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ ក្រោមអធិបតីភាព ឯកឧត្តម សេង សក្ដា អគ្គនាយក នៃអគ្គនាយកដ្ឋានការងារ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)។



ឯកឧត្តមរដ្ឋមន្ត្រី អ៊ិត សំហេង ជាអធិបតីក្នុងពិធីប្រជុំ

ជាកិច្ចចាប់ផ្ដើមកម្មវិធី លោក អ៊ុក សមវិទ្យា នាយកប.ស.ស បានមានប្រសាសន៍ថា សម្រាប់ឆ្នាំ២០១៤ បេឡាជាតិរបបសន្តិសុខសង្គម បានទទួលចុះបញ្ជិកា សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតនៅតាមបណ្ដារាជធានី ខេត្តបានចំនួន ៩៣៤ សហគ្រាស ដែលមានកម្មករនិយោជិតចំនួន ១៧៤.៩១៣នាក់។



ឯកឧត្តមរដ្ឋមន្ត្រី ថ្លែងក្នុងកិច្ចប្រជុំ

លោកបន្តថា នៅក្នុងឆ្នាំ២០១៤ កន្លងទៅមានកម្មករនិយោជិតនៅតាមបណ្ដាសហគ្រាស គ្រឹះស្ថាននៅរាជធានី និងតាមខេត្តមួយចំនួន បានទទួលរងគ្រោះរហូតដល់ស្លាប់បាត់បង់ជីវិតចំនួន ៩៥នាក់ និងរបួសចំនួន ១៩.៤២៥នាក់ នៅក្នុងខណៈពេលធ្វើដំណើរ និងក្នុងពេលបម្រើការងារ។ ចំពោះហានិភ័យការងារមានចំនួន ១៩.៤២៥នាក់, អង្កេតហានិភ័យការងារចំនួន ១៩.១១១នាក់ ក្នុងនោះមានគ្រោះថ្នាក់ការងារចំនួន ១៨.៦៩៩នាក់ (ស្រី ១៣.៨២០នាក់) ។

លោកនាយកបានបញ្ជាក់ថា គ្រោះថ្នាក់នៅកន្លែងធ្វើការចំនួន ១៤.០២២នាក់, នៅពេលធ្វើដំណើរចំនួន ៤.៦៧៤នាក់ និងជំងឺវិជ្ជាជីវៈចំនួន ៣នាក់ ក្នុងនោះមានរបួសស្រាលចំនួន ១៧.២១៤



សមាជិក សមាជិកា ចូលរួមក្នុងកិច្ចប្រជុំ




ឯកឧត្តម សេង សក្តា ថ្លែងក្នុងកិច្ចប្រជុំ




លោក អ៊ុក សមវិទ្យា អានរបាយការណ៍ស្វាគមន៍

នាក់ ធ្ងន់ចំនួន ១.៣៨៧នាក់, ស្លាប់ចំនួន ៩៥នាក់ មិនមែនជាគ្រោះថ្នាក់ការងារចំនួន ៤១២នាក់ ក្នុងនោះស្រីចំនួន ៣១៨នាក់។ លោកបានបន្ថែមថា ប.ស.ស បានសម្រេចបើកផ្តល់តាវកាលិកហានិភ័យការងារជូន កម្មករនិយោជិត មានតាវកាលិកព្យាបាល, តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន, តាវកាលិកបាត់បង់សមត្ថភាពអចិន្ត្រៃយ៍, តាវកាលិកឧត្តរជីវី, វិភាជន៍បូជាសព, តាវកាលិកអ្នកចាំថែរក្សា និងសេវាបុនទីតិសម្បទា ដែលចំណាយថវិកាចំនួន ៧.៩៨៧.០៦៩.៦០០រៀល។

ក្នុងកិច្ចប្រជុំនេះដែរ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានមានប្រសាសន៍ថា ការអនុវត្តរបបសន្តិសុខសង្គម ក្នុងផ្នែកហានិភ័យការងារនេះ ប.ស.ស ត្រូវពង្រឹង និងអភិវឌ្ឍគោលនយោបាយហានិភ័យឱ្យបានល្អប្រសើរ។ លោកបានបញ្ជាក់ថា ផ្នែកហានិភ័យការងារត្រូវពង្រីកពង្រឹងឱ្យបានកាន់តែល្អបន្ថែមទៀត ដើម្បីធានាផ្តល់សេវា ឱ្យមានប្រសិទ្ធភាព បានទាន់ពេលវេលា ដល់សមាជិករបស់ខ្លួន និងត្រូវរៀបចំវិធានការបង្ការគ្រោះថ្នាក់ការងារដើម្បីកាត់បន្ថយគ្រោះថ្នាក់ការងារឱ្យនៅកម្រិតទាបបំផុត។

ឯកឧត្តមរដ្ឋមន្ត្រី បានបញ្ជាក់បន្ថែមថា ត្រូវអនុវត្តផ្នែកថែទាំសុខភាព, ផ្នែកប្រាក់សោធន, ក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ បន្តជួយជ្រោមជ្រែង គាំទ្រសហការបន្ថែមទៀត ក្នុងការអភិវឌ្ឍវិស័យសន្តិសុខសង្គមនៅកម្ពុជា។ និយោជិក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ត្រូវចូលរួមអនុវត្តច្បាប់ឱ្យបានល្អ និងកម្មករនិយោជិត ត្រូវយល់អំពីសិទ្ធិ និងអត្ថប្រយោជន៍របស់ខ្លួន ដែលមានចែងនៅក្នុងច្បាប់ផងដែរ៕











វេទិកាសំណួរ ចំលើយដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងអង្គពិធី

# ដំណើរទស្សនកិច្ចសិក្សាដើម្បីស្វែងយល់អំពីប្រព័ន្ធសោធន នៅប្រទេសជប៉ុន





ជំនួបពិភាក្សារវាងថ្នាក់ដឹកនាំ ប.ស.ស ជាមួយក្រសួង ស្ថាប័ន អង្គភាពទាក់ទងនឹងការអនុវត្តរបបសន្តិសុខសង្គម និងការអនុវត្តរបបប្រាក់សោធន នៅប្រទេសជប៉ុន

លោក អ៊ុក សមវិទ្យា នាយកបេឡាជាតិរបបសន្តិសុខសង្គម រួមដំណើរដោយលោក ម៉េង ហុង នាយករង និងលោក គាត ពុធណារិទ្ធ ប្រធានការិយាល័យព័ត៌មានវិទ្យា នៃប.ស.ស អញ្ជើញទៅទស្សនកិច្ចសិក្សាស្វែងយល់អំពីប្រព័ន្ធសោធន នៅប្រទេសជប៉ុន រយៈពេល០៦ថ្ងៃ ពីថ្ងៃទី០៩ ដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៥។

ក្នុងដំណើរទស្សនកិច្ចសិក្សានេះ បានជួបពិភាក្សាការងារ នៅមជ្ឈមណ្ឌលនៃសហប្រតិបត្តិការអន្តរជាតិសម្រាប់កុំព្យូទ័ររូបនីយកម្ម (CICC), ដែលជាអង្គភាពចំណុះក្រសួងសេដ្ឋកិច្ចពាណិជ្ជកម្ម និងឧស្សាហកម្ម (METI), និងទទួលបន្ទុកត្រួតពិនិត្យរាល់ការនាំយកបច្ចេកវិទ្យាព័ត៌មានវិទ្យាជប៉ុនទៅប្រើប្រាស់នៅក្រៅប្រទេស និងមានការចូលរួមពី ក្រសួងសុខាភិបាលការងារ និងសុខុមាលភាព (MHLW), សេវាកម្មសោធនជប៉ុន (JPS), ក្រុមហ៊ុនអ៊ីតាឈី (HITACHI, Co.Ltd), និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ (JICA)។

ជំនួបពិភាក្សាជាមួយស្ថាប័ន អង្គភាពខាងលើ លោកនាយក ប.ស.ស បានជម្រាបពីគោលបំណង នៃការរៀបចំដំណើរការរបបប្រាក់សោធនសម្រាប់កម្មករនិយោជិត ក្នុងវិស័យឯកជន និងការអនុវត្តប្រព័ន្ធសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា។ បន្ទាប់ពីបានទទួលព័ត៌មាននេះ ស្ថាប័ន អង្គភាពទាំងនេះបានធ្វើការចំណាប់អារម្មណ៍គាំទ្រនូវដំណើរការនេះផងដែរ និងបានសន្យាថានឹងជួយរៀបចំប្រព័ន្ធដល់កម្ពុជា សម្រាប់ការគ្រប់គ្រងប្រព័ន្ធសោធនឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកវិទ្យា។

ក្នុងជំនួបជាមួយលោក NAKAMURA Shintaro ទីប្រឹក្សាជាន់ខ្ពស់ផ្នែកសន្តិសសុខសង្គមរបស់ JICA បានសួរសំណួរជាច្រើនទាក់ទងនឹងការអនុវត្តប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជា ជាពិសេសការអនុវត្តផ្នែកប្រាក់សោធន។ លោកនាយកក៏បានជម្រាបជូនអំពីស្ថានភាពទូទៅនៃប្រព័ន្ធសន្តិសុខសង្គមកម្ពុជា ដោយផ្តោតសំខាន់លើការអនុវត្តរបបសន្តិសុខសង្គម អំពីការរៀបចំដំណើរការរបបប្រាក់សោធន ជាពិសេសទាក់ទងនឹងការគ្រប់គ្រងប្រវត្តិបណ្ណសាររបស់កម្មករនិយោជិត និងការគណនាអត្រាភាគទានតាមបែបគណិតវិទ្យាឱ្យបានត្រឹមត្រូវ។

ក្នុងនោះលោក NAKAMURA Shintaro ក៏បានលើកឡើងពីបទពិសោធន៍នៃការគ្រប់គ្រងប្រព័ន្ធសន្តិសុខសង្គម ជាពិសេសប្រព័ន្ធប្រាក់សោធននៅជប៉ុន និងបានសួរថា សម្រាប់ការរៀបចំដំណើរការរបបសោធននៅកម្ពុជា តើចង់ឱ្យជប៉ុនជួយលើផ្នែកណាខ្លះ។ ក្នុងឱកាសនោះលោកនាយកបានលើកឡើងនូវសំណើសុំជំនួយផ្នែកបច្ចេកទេសលើពីរចំណុច គឺការរៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងប្រព័ន្ធសោធន និងអ្នកជំនាញ (Actuary) ផ្នែកសិក្សាវិភាគវាយតម្លៃលើអត្រាភាគទាន និងតារាកាលិក។ បន្ទាប់ពីបានពិនិត្យលើសំណើនេះ ជាគោលការណ៍ លោកបានឯកភាព និងស្នើឱ្យមានការស្នើសុំជាផ្លូវការមួយពីរាជរដ្ឋាភិបាលកម្ពុជាទៅរាជរដ្ឋាភិបាលជប៉ុន ដោយធ្វើការទំនាក់ទំនងជាមួយ JICA នៅកម្ពុជា។

សរុបមកដំណើរទស្សនកិច្ចសិក្សារយៈពេល ៦ថ្ងៃនេះ ថ្នាក់ដឹកនាំព្រមទាំងសហការីទទួលបាននូវចំណេះដឹង និងបទពិសោធន៍ថ្មីៗថែមទៀតលើផ្នែកសន្តិសុខសង្គម ជាពិសេសបានដឹងពីប្រព័ន្ធគ្រប់គ្រងប្រាក់សោធនរបស់ជប៉ុនផងដែរ៕



ទិដ្ឋភាពនៃការផ្តល់វត្ថុអនុស្សាវរីយ៍ និងការថតរូបអនុស្សាវរីយ៍



# កិច្ចប្រជុំផ្សព្វផ្សាយអប់រំ ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅរោងចក្រ ELITE (Cambodia) Co.,Ltd ខេត្តស្វាយរៀង



ឧត្តមសេនីយ៍ត្រី លុយ ឈីន ចូលរួមជាអធិបតីក្នុងពិធីប្រជុំ

បញ្ហាគ្រោះថ្នាក់ចរាចរណ៍បានក្លាយជាក្តីកង្វល់យ៉ាងធំ និងជាការព្រួយបារម្ភដ៏ខ្លាំងរបស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួង/ស្ថាប័ន អង្គភាពពាក់ព័ន្ធ ជាពិសេស ប.ស.ស បានសិក្សាស្រាវជ្រាវរកដំណោះស្រាយក្នុងការទប់ស្កាត់ កាត់បន្ថយគ្រោះថ្នាក់ដែលកើតឡើងជាយថាហេតុនេះឱ្យនៅកម្រិតទាបបំផុត ដែលបានកើតឡើងចំពោះសមាជិក ប.ស.ស។ គ្រោះថ្នាក់ចរាចរណ៍នៅតែបន្តកើតមានឡើងឥតឈប់ បានបណ្តាលឲ្យមានអ្នករងរបួស និងស្លាប់យ៉ាងអាណោចអាធ័ម។

ស្របជាមួយគ្នានេះកាលពីព្រឹកថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥ ក្រុមការងារ ស.ផ.ក បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំ និងស្រង់ស្ថិតិដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត នៅរោងចក្រ ELITE (CAMBODIA) CO.,Ltd តំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន ខេត្តស្វាយរៀង។ កិច្ចប្រជុំប្រព្រឹត្តទៅក្រោមអធិបតីលោកឧត្តមសេនីយ៍ត្រី លុយ ឈីន អនុប្រធានក្រុមការងារ ស.ផ.ក លោក ជាវ ប៊ុនរិទ្ធ សមាជិកក្រុមការងារ ស.ផ.ក និងមានការចូលរួមរបស់អភិបាលក្រុងបាវិត ប្រធានសមាគមសុវត្ថិភាពដឹកជញ្ជូនអ្នកដំណើរខេត្តស្វាយរៀងអ្នកបើកបរយានយន្តដឹកកម្មករនិយោជិត និងកម្មករនិយោជិតជាច្រើននាក់ទៀត។

លោកឧត្តមសេនីយ៍ត្រី លុយ ឈីន អនុប្រធានក្រុមការងារ ស.ផ.ក បានធ្វើបទបង្ហាញ ស្តីពីសុវត្ថិភាពចរាចរណ៍ ផ្លូវគោក បច្ចេកទេសត្រួតពិនិត្យយានយន្ត និងវិជ្ជាសង្គ្រោះបឋមមុនពេលបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ។ លោកក៏បានអំពាវនាវដល់អ្នកដែលគ្មានប័ណ្ណបើកបរ ត្រូវធ្វើការទំនាក់ទំនងជាមួយប្រធានសមាគមអ្នកបើកបរដឹកកម្មករនិយោជិត ប្រចាំតំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន ដើម្បីទទួលបានការបំប៉នផ្នែកទ្រឹស្តីច្បាប់ចរាចរណ៍ផ្លូវគោកពីក្រុមការងារ ស.ផ.ក និងត្រូវអនុវត្តឲ្យមានប្រសិទ្ធភាព។

លោកឧត្តមសេនីយ៍ត្រី បានបន្ថែមទៀតថា តាមរបាយការណ៍របស់ក្រសួងមហាផ្ទៃ បញ្ហាគ្រោះថ្នាក់ភាគច្រើន គឺផ្តើមចេញពីការបើកបរមានល្បឿនលឿន (ល្មើសល្បឿន) បើកបរក្រោមឥទ្ធិពលស្រវឹង បើកបរខ្វេសប្រហែស និងមានកត្តាគួបផ្សំជាច្រើនទៀតដែលបណ្តាលឱ្យមានគ្រោះថ្នាក់។ ជាងនេះទៅទៀតក្រុមការងារមានគោលការណ៍ពិសេសពីក្រសួងសាធារណការ និងដឹកជញ្ជូនដើម្បីសុំសិទ្ធិប្រឡងយកប័ណ្ណបើកបរ ជូនអ្នកបើកបរដឹកកម្មករនិយោជិតឲ្យបានចូលរៀន និងប្រឡងយកប័ណ្ណបើកបរទាំងអស់គ្នា ដើម្បីទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ដែលផ្តោតសំខាន់ទៅលើគ្រោះថ្នាក់ពេលធ្វើដំណើរពីកន្លែងធ្វើការទៅផ្ទះ និងពីផ្ទះទៅកន្លែងធ្វើការរបស់កម្មករនិយោជិតផងដែរ៕



សិក្ខាកាមដែលជាអ្នកបើកបរដឹកកម្មករនិយោជិតចូលរួមក្នុងអង្គពិធី

# បេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំ ដល់អ្នកបើកបរយានយន្ត ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោកថ្មី នៅខេត្តកំពង់ឆ្នាំង


ការធ្វើបទបង្ហាញរបស់ឧត្តមសេនីយ៍ត្រី លុយ ឈីន ក្នុងកិច្ចប្រជុំ

នៅព្រឹកថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៥ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) នៃបេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្តីពីច្បាប់ចរាចរណ៍ផ្លូវគោកថ្មី ដល់អ្នកបើកបរដឹកកម្មករនិយោជិត នៅរោងចក្រ Tripos International (CAMBODIA) Co.,Ltd ដែលមានទីតាំងស្ថិត នៅខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាពលោកឧត្តមសេនីយ៍ត្រី លុយ ឈីន អនុប្រធានគណៈកម្មការ ស.ផ.ក និងលោក ជាវ ប៊ុនរិទ្ធ សមាជិកក្រុមការងារ ស.ផ.ក ព្រមទាំងមានការចូលរួមពីរដ្ឋបាលរោងចក្រ និងអ្នកបើកបរដឹកកម្មករនិយោជិតជាច្រើន។


សិក្ខាកាមដែលជាអ្នកបើកបរដឹកម្មករនិយោជិតចូលរួមក្នុងកិច្ចប្រជុំស្តីពីច្បាប់ចរាចរណ៍ផ្លូវគោកថ្មី

ក្នុងឱកាសនេះដែរ លោកឧត្តមសេនីយ៍ត្រី លុយ ឈីន អនុប្រធានក្រុមការងារស.ផ.កធ្វើបទបង្ហាញស្តីពីចរាចរណ៍ផ្លូវគោក បច្ចេកទេសត្រួតពិនិត្យយានយន្ត និងវិជ្ជាសង្គ្រោះបឋមមុនពេលបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ។ លោកក៏បានបញ្ជាក់បន្ថែមថា ដោយមើលឃើញពីស្ថានភាពគ្រោះថ្នាក់ចរាចរណ៍នៅតែបន្តកើតមានឡើងឥតឈប់ បានបណ្តាលឱ្យមានអ្នកស្លាប់ របួស ពិការ និងបន្សល់ទុកនូវសោធនាដកម្មយ៉ាងអាណោចអាធ័មជាទីបំផុត។

ដូចនេះគោលបំណងនៃកិច្ចប្រជុំផ្សព្វផ្សាយនេះ គឺផ្តោតសំខាន់ទៅលើច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោកថ្មី និងវិជ្ជាសង្គ្រោះបឋមបច្ចេកទេសត្រួតពិនិត្យយានយន្ត និងបញ្ហាប្រឈមក្នុងឆ្នាំ២០១៤ កន្លងមក។ ស្របជាមួយគ្នានេះក្រុមការងារទទួលបានគោលការណ៍ពិសេសពីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីសុំសិទ្ធិប្រឡងយកប័ណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករនិយោជិត ឱ្យបានចូលរៀន និងបានប្រឡងយកប័ណ្ណបើកបរទាំងអស់គ្នា៕


ឧត្តមសេនីយ៍ត្រី លុយ ឈីន ផ្តល់សំនួរ-ចំលើយ ទាក់ទងនឹងច្បាប់ចរាចរណ៍

# កិច្ចប្រជុំ ស្តីពីការអនុវត្តគោលនយោបាយថ្មីៗ និងពង្រឹងសេវា នៃការផ្តល់តាវកាលិកហានិភ័យការងារ នៅខេត្តកំពង់ស្ពឺ

កាលពីថ្ងៃទី១៩ ខែកុម្ភៈ ២០១៥ បេឡាជាតិរបបសន្តិសុខសង្គម បានបើកកិច្ចប្រជុំ ស្តីពីការអនុវត្តគោលនយោបាយថ្មីៗ និងពង្រឹងសេវានៃការផ្តល់តាវកាលិកហានិភ័យការងារជូនកម្មករ និយោជិត ដែលប្រារពធ្វើឡើងនៅសាលប្រជុំសណ្ឋាគារហ្វលីដេ ខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាព លោក ម៉េង ហុង នាយករងបេឡាជាតិរបបសន្តិសុខសង្គម លោក ជាវ ប៊ុនរិទ្ធ ប្រធានការិយាល័យគោលនយោបាយ និងប្រធានសាខា ប.ស.ស ខេត្តកំពង់ស្ពឺ



បទបង្ហាញ លោក ជាវ ប៊ុនរិទ្ធ ស្តីពីការអនុវត្តគោលនយោបាយថ្មីៗ

ព្រមទាំងមានការចូលរួមពី លោក លោកស្រី តំណាងនិយោជក នាយក ម្ចាស់ សហគ្រាស គ្រឹះស្ថាន និងជនរងគ្រោះអ្នកនៅក្នុងបន្ទុកដោយគ្រោះថ្នាក់ ការងារ (ឧត្តរជីវី) ជាច្រើនទៀត។

គោលបំណង នៃកិច្ចប្រជុំនេះផ្តោតសំខាន់ទៅលើការផ្តល់សេវារបស់មន្ទីរពេទ្យ សេវារបស់ធនាគារអេស៊ីលីដាភីអិលស៊ី សេវារបស់សាខា ប.ស.ស ខេត្ត និងអត្ថប្រយោជន៍ផ្សេងៗទៀត ដូចមានចែងក្នុងច្បាប់ បង្កើនការយល់ដឹងក្នុងការអនុវត្ត និងសិទ្ធិក្នុងការទទួលបានតាវការលិក ជាពិសេសការចូលរួមពីគ្រប់ភាគីក្នុងការដោះស្រាយបញ្ហារួមគ្នា ដើម្បីអភិវឌ្ឍន៍កិច្ចដំណើរការប្រព្រឹត្តទៅរបស់ ប.ស.ស ក្នុងការបម្រើសេវាសាធារណៈជូនដល់កម្មករនិយោជិតឱ្យមានប្រសិទ្ធភាពខ្ពស់បន្ថែមទៀត។

បន្ទាបមក លោក ម៉េង ហុង បានផ្តាំផ្ញើ និងបានសំណូមពរឲ្យសហគ្រាស គ្រឹះស្ថាន ធ្វើការប្រកាសចំនួនកម្មករការបង់ភាគទានឲ្យបានត្រឹមត្រូវព្រោះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្កើតក្រុមការងារអធិការ កិច្ចចម្រុះ ដើម្បីចុះត្រួតពិនិត្យតាមបណ្តារោងចក្រ សហគ្រាសទាំង២៥រាជធានី/ខេត្ត។ កន្លងមកមានរោងចក្រ សហគ្រាស គ្រឹះស្ថានមួយចំនួនបានលាក់នូវចំនួនកម្មករ បង់ភាគទានមិនបានត្រឹមត្រូវ។ លោកបានចណូមពរឱ្យសមាជិក ដែលបានចូលរួមកិច្ចប្រជុំនាថ្ងៃនេះ សូមជួយធ្វើការផ្សព្វផ្សាយដល់បុគ្គលិក ដែលបានរៀបអាពាហ៍ពិពាហ៍រួចត្រូវធ្វើសំបុត្រអាពាហ៍ពិពាហ៍ ព្រោះនៅក្នុងខេត្តនេះជាក់ស្តែងមានករណីគ្រោះថ្នាក់ការងារ ដល់បាត់បង់ជីវិតជាច្រើនករណីដែលមិនបានទទួលតាវកាលិកឧត្តរជីវីពី ប.ស.ស ដោយសារពួកគាត់មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍៕



សិក្ខាកាមដែលជាតំណាងនិយោជក ម្ចាស់ សហគ្រាស គ្រឹះស្ថាន ចូលរួមក្នុងកិច្ចប្រជុំ ស្តីពីការអនុវត្តគោលនយោបាយថ្មីៗ

# ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក ចុះផ្សព្វផ្សាយអប់រំ ដល់អ្នកបើកបរ អំពី ការគោរពច្បាប់ចរាចរណ៍ នៅរោងចក្រ SIXPLUS INDUSTRY CO.,Ltd ខេត្តកណ្តាល

កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំ ដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត នៅរោងចក្រ Sixplus Industry CO.,Ltd មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៦A ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល។ កិច្ចប្រជុំរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអប់រំ និងស្រង់ស្ថិតិ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងចំនួនអ្នកបើកបរយានយន្តដឹកកម្មករនិយោជិត និងធ្វើការផ្សព្វផ្សាយអប់រំទប់ស្កាត់ កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ (គ្រោះថ្នាក់ការងារ) ឱ្យបានទូលំទូលាយ ដល់អ្នកបើកបរ។ កិច្ចប្រជុំប្រព្រឹត្តទៅក្រោមអធិបតី លោកស្រី បុប្ផា ផានី សមាជិកក្រុមការងារ ស.ផ.ក លោក ជាវ ប៊ុនរិទ្ធ សមាជិកក្រុមការងារ ស.ផ.ក រួមទាំងអ្នកបើកបរយានយន្តដឹកកម្មករនិយោជិត និងកម្មករនិយោជិតយ៉ាងច្រើន។




លោកស្រី បុប្ផា ផានី ចូលរួមជាអធិបតីក្នុងពិធីប្រជុំផ្សព្វផ្សាយអប់រំ ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក

ក្នុងឱកាសនេះដែរ លោកស្រី បុប្ផា ផានី សមាជិកក្រុមការងារ ស.ផ.ក បានធ្វើបទបង្ហាញស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក បច្ចេកទេសត្រួតពិនិត្យយានយន្ត និងវិជ្ជាសង្គ្រោះបឋមមុនពេលបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ។ លោកស្រីបានបញ្ជាក់បន្ថែមថា ដោយមើលឃើញអំពីស្ថានភាពគ្រោះថ្នាក់ចរាចរណ៍កើតមានជារៀងរាល់ថ្ងៃ ជាពិសេសទៅលើកម្មករនិយោជិត ទើបថ្ងៃនេះបេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំកិច្ចប្រជុំនៅរោងចក្រ Sixplus Industry Co.,Ltd នេះ ជាលើកទី៣ សម្រាប់ឆ្នាំ២០១៥ ដើម្បីឱ្យកម្មករនិយោជិតយល់ដឹងអំពីច្បាប់ស្តីពីចរាចរណ៍ និងគោរពច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឲ្យបានខ្ជាប់ខ្ជួន៕



សិក្ខាកាមដែលជាអ្នកបើកបរយានយន្តដឹកកម្មករនិយោជិតចូលរួមក្នុងពិធីប្រជុំ

# កិច្ចប្រជុំផ្សព្វផ្សាយអប់រំ ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅរោងចក្រ A & J ( Cambodia ) Co.,Ltd ខេត្តស្វាយរៀង

កាលពីថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៥ ក្រុមការងារ ស.ផ.ក បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំ និងស្រង់ស្ថិតិដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត នៅរោងចក្រ A & J (CAMBODIA) CO.,Ltd តំបន់សេដ្ឋកិច្ចពិសេសតាយសេង មានទីតាំងស្ថិតនៅក្រុងបាវិត ក្នុងខេត្តស្វាយរៀង។ កិច្ចប្រជុំប្រព្រឹត្តទៅក្រោមការដឹកនាំដោយលោកឧត្តមសេនីយ៍ត្រី លុយ ឈីន អនុប្រធានក្រុមការងារ ស.ផ.ក លោក ជាវ ប៊ុនរិទ្ធ សមាជិកក្រុមការងារ ស.ផ.ក រួមទាំងអ្នកបើកបរយានយន្តដឹកកម្មករនិយោជិត និងកម្មករនិយោជិតយ៉ាងច្រើន។ កិច្ចប្រជុំរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអប់រំ និងស្រង់ស្ថិតិ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងចំនួនអ្នកបើកបរយានយន្តដឹកកម្មករនិយោជិត និងចូលរួមផ្សព្វផ្សាយអប់រំទប់ស្កាត់ កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ (គ្រោះថ្នាក់ការងារ)។




ឧត្តមសេនីយ៍ត្រី លុយ ឈីន ចូលរួមជាអធិបតីក្នុងពិធីប្រជុំ

ស្របជាមួយគ្នានេះលោកឧត្តមសេនីយ៍ត្រី លុយ ឈីន អនុប្រធានក្រុមការងារស.ផ.ក បានធ្វើបទបង្ហាញច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បច្ចេកទេសត្រួតពិនិត្យយានយន្ត និងវិជ្ជាសង្គ្រោះបឋមមុនពេលបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ។ លោកបានអំពាវនាវដល់អ្នកដែលគ្មានប័ណ្ណបើកបរ ត្រូវធ្វើការទំនាក់ទំនងជាមួយប្រធានសមាគមអ្នកបើកបរដឹកកម្មករនិយោជិតប្រចាំតំបន់សេដ្ឋកិច្ចពិសេសនេះ ដើម្បីទទួលបានការបំពាក់បំប៉ននូវច្បាប់ចរាចរណ៍ផ្លូវគោកពីក្រុមការងារ ស.ផ.ក និងត្រូវអនុវត្តឲ្យបានខ្ជាប់ខ្ជួន។ ជាងនេះទៅទៀតក្រុមការងារទទួលបានគោលការណ៍ពិសេសពីក្រសួងសាធារណការ និងដឹកជញ្ជូនដើម្បីសុំសិទ្ធិប្រឡងយកប័ណ្ណបើកបរ ជូនអ្នកបើកបរដឹកកម្មករនិយោជិតឲ្យបានចូលរៀន និងប្រឡងយកប័ណ្ណបើកបរទាំងអស់គ្នា ដើម្បីទប់ស្កាត់កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ដែលផ្តោតសំខាន់ទៅលើគ្រោះថ្នាក់ពេលធ្វើដំណើរពីកន្លែងធ្វើការទៅផ្ទះ និងពីផ្ទះទៅកន្លែងធ្វើការរបស់កម្មករនិយោជិតឱ្យមានប្រសិទ្ធភាព៕



ការចូលរួមរបស់សិក្ខាកាម (អ្នកបើកបរ) ក្នុងអង្គពិធី

# ការកំណត់ចំនួនរោងចក្រសម្រាប់ប្រជុំផ្សព្វផ្សាយអប់រំឆ្នាំ២០១៥ អំពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ លក្ខខណ្ឌការងារ អត្ថប្រយោជន៍ បេឡាជាតិរបបសន្តិសុខសង្គម និង សុវត្ថិភាព លើមធ្យោបាយដឹកជញ្ជូនកម្មករ



កិច្ចប្រជុំពិភាក្សាការងាររបស់ក្រុមការងារ ទ.ស.ប.ក

ដើម្បីធ្វើការផ្សព្វផ្សាយឱ្យបានទូលាយ ទាំងបរិមាណ និងគុណភាព យើងត្រូវកំណត់ទិន្នន័យ និងទីតាំងដែលត្រូវផ្សព្វផ្សាយនោះឱ្យបានច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ។ ជាពិសេសទៅលើសហគ្រាស គ្រឹះស្ថានណាដែលទើបបង្កើតថ្មី និងសហគ្រាសណាដែលមិនទាន់បានផ្សព្វផ្សាយនៅឡើយ។

ការកំណត់ចំនួនរោងចក្រសម្រាប់ប្រជុំផ្សព្វផ្សាយ ដើម្បីធ្វើការទប់ស្កាត់ និងការពារគ្រោះថ្នាក់ការងារដែលកើតឡើង និងករណីសន្លប់ដែលកើតមាននៅតាមបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថានឱ្យស្ថិតនៅកម្រិតមួយទាបបំផុតដែលអាចទៅបាន។

ស្របគ្នានេះ កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៥ ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ ទ.ស.ប.ក បានបើកកិច្ចប្រជុំរបស់ខ្លួនជាលើកទី២ ស្តីពីការកំណត់ចំនួនរោងចក្រ សម្រាប់ប្រជុំផ្សព្វផ្សាយអប់រំឆ្នាំ២០១៥ អំពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ លក្ខខណ្ឌការងារ អត្ថប្រយោជន៍បេឡាជាតិរបបសន្តិសុខសង្គម និងសុវត្ថិភាពលើមធ្យោបាយដឹកជញ្ជូនកម្មករ។

កិច្ចប្រជុំបានប្រព្រឹត្តទៅក្រោមការដឹកនាំដោយ ឯកឧត្តមវេជ្ជ. ប៉ុក វណ្ណថាត ប្រធានក្រុមការងារ និងមានសមាជិកមកពីផ្នែកពាក់ព័ន្ធជាច្រើនរូបទៀត។ អង្គប្រជុំបានឯកភាពសម្រេចជាលទ្ធផល ដោយមានការឯកភាពគ្នាទាំងស្រុងទៅតាមសំណូមពរ របស់សមាជិក សមាជិកាក្នុងអង្គប្រជុំដូចជា៖

-ឱ្យមានការកំណត់កាលបរិច្ឆេទ ឬដាក់កម្មវិធីប្រជុំតាមបណ្តារោងចក្រឱ្យបានច្បាស់លាស់។

- ក្នុងមួយខែគួរចុះផ្សព្វផ្សាយពី ៨រោងចក្រ ទៅ១០ រោងចក្រ តែខែខ្លះអាចតិចជាងនេះ ឬច្រើនជាងនេះ

- អញ្ជើញផ្នែកពាក់ព័ន្ធចូលរួមឱ្យបានច្រើន ពេលបញ្ចប់ការផ្សព្វផ្សាយ គួរត្រូវបានធ្វើ Check list (យល់ មិនយល់ យល់ខ្លះ) ជាដើម។



# ដំណើរឆ្ពោះទៅមុខរបស់ស្ត្រីកម្ពុជាក្រោមសន្និសីទស្ត្រីពិភពលោក ទិវានារីអន្តរជាតិ



លោក អ៊ុក សមវិទ្យា នាយក ប.ស.ស រៀបចំពិធីអបអរ០៨មីនា ទិវានារីអន្តរជាតិ

នារសៀលថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៥ បេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំពិធីអបអរនារីអន្តរជាតិ (International Women's Rights Day) ខួបលើក ១០៥ លើប្រធានបទដំណើរទៅមុខៈ ស្ត្រីកម្ពុជាក្រោយសន្និសីទស្ត្រីពិភពលោក ក្រោមការដឹកនាំដោយ លោក អ៊ុក សមវិទ្យា នាយកបេឡាជាតិរបបសន្តិសុខសង្គម និងសិក្ខាកាមដែលជាមន្ត្រីបុគ្គលិក ប.ស.ស ចូលរួមជាច្រើនរូបទៀត។ ពិធីនេះធ្វើឡើងដើម្បីរំលឹកដល់សន្និសីទទីក្រុងប៉េកាំង ដែលត្រូវបានចាត់ទុកជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយសម្រាប់ស្ត្រី។ ដោយក្នុងពេលរដ្ឋាភិបាល ១៨៩ បានយល់ព្រមចុះហត្ថលេខា លើរបៀបវារៈក្នុងការផ្តល់សិទ្ធិសេរីភាពជូន ដល់ស្ត្រី។

គោលបំណងនៃប្រធានបទនេះ គឺធ្វើការបំផុស និងកៀងគរប្រជាពលរដ្ឋទាំងអស់នៅក្នុងប្រទេសកម្ពុជា ឱ្យធ្វើការរួមគ្នាដើម្បីឱ្យសម្រេចបាននូវសមភាពដ៏ពិតប្រាកដរវាងបុរស និងស្ត្រី ក៏ដូចជាឱ្យមានការទទួលស្គាល់ថាស្ត្រី គឺជាភ្នាក់ងារដ៏សំខាន់ដែលមានតួនាទីធ្វើឱ្យសង្គមផ្លាស់ប្តូរប្រែមុខមាត់ថ្មី។

ពិធីនេះ គឺផ្តោតទៅលើ ១២ចំណុច ដើម្បីទាញចក្ខុវិស័យ



សិក្ខាកាមដែលជាមន្ត្រីបុគ្គលិក ប.ស.ស ចូលរួមក្នុងពិធី

ពិភពលោក ឱ្យផ្តោតទៅលើស្ត្រី និងកុមារី ដើម្បីឱ្យពួកគេអាចរួមចំណែកក្នុងសកម្មភាពនយោបាយ ទទួលបានការអប់រំ ទទួលបានប្រាក់ចំណូល និងរស់នៅក្នុងសង្គមដែលគ្មានអំពើហិង្សា និងការរើសអើងគ្នា។



ពិធីប្រគល់រង្វាន់លើកទឹកចិត្ត ដល់មន្ត្រី បុគ្គលិក ប.ស.ស ដែលជានារីក្នុងអង្គពិធី

# កិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ លក្ខខណ្ឌការងារ អត្ថប្រយោជន៍របបសន្តិសុខសង្គម នៅខេត្តព្រះសីហនុ

ករណីសន្លប់របស់កម្មករនិយោជិត ពាក់ព័ន្ធកត្តាច្រើនយ៉ាង។ ពេលខ្លះមកពីបរិយាកាសមិនល្អទាំងក្នុង និងក្រៅកន្លែងធ្វើការ ការទទួលទានមិនគ្រប់គ្រាន់ ការធ្វើការលើសម៉ោង និងអនាម័យមិនល្អជាដើម។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជា ប.ស.ស បានយកចិត្តទុកដាក់ដោយធ្វើការទប់ស្កាត់ ករណី




កិច្ចប្រជុំពិភាក្សាតំណាងសហជីព និងរដ្ឋបាលរោងចក្រ

ស្លប់ឱ្យនៅកម្រិតមួយទាបដែលអាចទៅបាន តាមរយៈការផ្សព្វផ្សាយអប់រំណែនាំ។

ដោយសារករណីសន្លប់នៅតាមបណ្តារោងចក្រ សហគ្រាសគ្រឹះស្ថាន បានកើតមានឡើងជាញឹកញាប់ដែលជាក្តីកង្វល់យ៉ាងធំ និងជាការព្រួយបារម្ភដ៏ខ្លាំងរបស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងស្ថាប័ន អង្គភាពពាក់ព័ន្ធ ជាពិសេសបេឡាជាតិរបបសន្តិសុខសង្គម។ បច្ចុប្បន្នប.ស.ស បានសិក្សាស្រាវជ្រាវរកដំណោះស្រាយទប់ស្កាត់ កាត់បន្ថយករណីសន្លប់ឱ្យនៅកម្រិតទាបបំផុត។

ដូចគ្នានេះដែរ កាលពីរសៀលថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៥ ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ (ទ.ស.ប.ក) នៃបេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំ ស្តីពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ លក្ខខណ្ឌការងារ អត្ថប្រយោជន៍របបសន្តិសុខសង្គម និងសុវត្ថិភាពចរាចរណ៍លើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត នៅរោងចក្រ Heniemo (CAMBODIA) HOME TEXTILE CO.,Ltd ស្ថិតនៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ (តំបន់សេដ្ឋកិច្ចពិសេស) កិច្ចប្រជុំដឹកនាំដោយ លោក ហាន់ នព្វគុណ សមាជិកក្រុមការងារ លោក ជាវ ប៊ុនរិទ្ធ សមាជិកក្រុមការងារ និងមានកម្មករនិយោជិតចូលរួមជាច្រើនរូបទៀត។

គោលបំណងនៃកិច្ចប្រជុំផ្តោតលើការផ្សព្វផ្សាយអប់រំទប់ស្កាត់ និងបង្ការករណីសន្លប់របស់កម្មករនិយោជិត ឱ្យនៅកម្រិតទាប និងធ្វើការផ្សព្វផ្សាយអប់រំ ដល់ពួកគាត់បានយល់ដឹងអំពីលក្ខខណ្ឌការងារ លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ អត្ថប្រយោជន៍របបសន្តិសុខសង្គម និងសុវត្ថិភាពចរាចរណ៍ លើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត នៅពេលធ្វើដំណើរទៅមកពីកន្លែងធ្វើ ការទៅផ្ទះ និងពីផ្ទះទៅកន្លែងធ្វើការ។៕



កិច្ចប្រជុំពិភាក្សាតំណាងសហជីព និងរដ្ឋបាលរោងចក្រ



# ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ ទ.ស.ប.ក ចុះអង្កេតករណីសន្លប់ នៅរោងចក្រ GRAND EAST FOOTWEAR INT`L CORP

ករណីសន្លប់របស់កម្មករនិយោជិតចំនួន៦៣នាក់នេះ បើតាមការចុះអង្កេតរបស់ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ (ទ.ស.ប.ក) គឺបណ្តាលមកពីបរិយាកាសក្នុងអាគារផលិតកម្មមានសីតុណ្ហភាពក្តៅ ការប្រើប្រាស់សារធាតុគីមី (ការបិទស្បែកជើង) មិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងធុំក្លិនផ្សែងម្តងម្កាលស្ថិតនៅក្នុងអាគាររោងចក្រផងដែរ។

ករណីនេះកើតឡើងកាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ នៅ



ក្រុមការងារប្រជុំពិភាក្សាលើករណីសន្លប់ និងចុះអង្កេតនៅកន្លែងកើតហេតុ



រោងចក្រ GRAND EAST FOOTWEAR INT'L CORP ស្រុកអង្គស្នួល ខេត្តកណ្តាល។ តាមរបាយការណ៍របស់ក្រុមការងារបានឱ្យបានដឹងថា ការសន្លប់គឺផ្តើមចេញពីកម្មការិនីមានផ្ទៃពោះ ៧ខែម្នាក់មានអាការៈមិនស្រួលខ្លួន (វិលមុខ ធីងធោង ថប់ដង្ហើម ទន់ដៃទន់ជើង)។ បន្ទាប់មកបញ្ហានេះត្រូវបានកម្មការិនីផ្សេងទៀងឃើញ ក៏មានអារម្មណ៍ភិតភ័យ ស្លន់ស្លោ ហើយសន្លប់តៗគ្នារហូតដល់៦៣នាក់តែម្តង។

ក្រុមការងារ បានចុះទៅសម្របសម្រួលជាមួយផ្នែកពាក់ព័ន្ធ បញ្ជូនជនរងគ្រោះទៅសង្គ្រោះ និងព្យាបាលនៅមន្ទីរពេទ្យបង្អែកស្រុកអង្គស្នួលចំនួន ៣៣នាក់ និងមន្ទីរសម្រាកព្យាបាលសម្តេច



កិច្ចប្រជុំពិភាក្សារកមូលហេតុដែលបណ្តាឱ្យមានករណីសន្លប់

សុខាបែកចានចំនួន៣០នាក់។ រាល់ការចំណាយលើការដឹកជញ្ជូនជនរងគ្រោះ និងថ្លៃព្យាបាលជាបន្ទុក របស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)។

ក្រុមការងារបានធ្វើការអប់រំណែនាំ ដល់និយោជកឱ្យគោរពតាមលក្ខខណ្ឌការងារដូចជាៈ

-អនុញ្ញាតិឱ្យកម្មករចូលធ្វើការវិញតាមការពិនិត្យរបស់គ្រូពេទ្យប្រចាំនៅរោងចក្រ និងតាមការឃ្លាំមើលរបស់ផ្នែកពាក់ផ្សេងទៀត

-កែសម្រួលប្រព័ន្ធកង្ហារដែលមានស្រាប់ឱ្យត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស

-ត្រូវប្រុងប្រយ័ត្នក្នុងការប្រើប្រាស់កាវ (ប្រើហើយត្រូវបិទគំរបឱ្យបានជិតល្អ)

-ត្រូវផ្តល់សម្ភារៈការពារដល់កម្មករឱ្យបានខ្ជាប់ខ្ជួន (ពាក់ម៉ាស់ និងសម្ភារៈផ្សេងទៀត...)

-សង់បង្គន់ខ្វះចំនួន១៦ តាមប្រកាសលេខ០៥២ សកបយ

-អប់រំកម្មករនិយោជិតឱ្យយល់ដឹង និងអនុវត្តតាមការណែនាំអំពីរបបចំណីអាហារ

-ជ្រើសរើសគិលានុប្បដ្ឋាក ឬគិលានុប្បដ្ឋាយិកា០១នាក់បន្ថែម តាមប្រកាសរួមលេខ៣៣០ សកបយ

-ផ្អាកការបន្ថែមម៉ោងរហូត ដល់សុខភាពកម្មករវិលមកសភាពដើមវិញ។

ការប្រតិបត្តិការងារទទួលលទ្ធផលល្អទៅបាន លុះត្រាណាតែមានការសហការស្អិតរមួតរវាង ប.ស.ស និយោជក និងកម្មករនិយោជិតផ្ទាល់ផងដែរ ក្នុងការទប់ស្កាត់ករណីសន្លប់នេះ៕

# បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ប្រជុំផ្សព្វផ្សាយ ស្តីពីគោលនយោបាយថ្មីៗ និងពង្រឹងការផ្តល់សេវាតាវកាលិក នៅខេត្តឧត្តរមានជ័យ



មន្ត្រីប.ស.ស ខេត្តឡើងអានរបាយការណ៍



លោក ម៉េង ហុង ធ្វើបទបង្ហាញក្នុងអង្គពិធី

នៅព្រឹកថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥ បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយគោលនយោបាយថ្មីៗ និងពង្រឹងសេវា នៃការផ្តល់តាវកាលិកហានិភ័យការងារជូនកម្មករនិយោជិត ក្រោមអធិបតីភាព លោក ម៉េង ហុង នាយករង ប.ស.ស និងសាខា ប.ស.ស ខេត្តឧត្តរមានជ័យ និងមានការចូលរួមពីនាយក ម្ចាស់ ឬតំណាង សហគ្រាស គ្រឹះស្ថាន មន្ទីរពេទ្យចុះកិច្ចព្រមព្រៀង ធនាគារអេស៊ីលីដា នៅក្នុងខេត្តឧត្តរមានជ័យ ។

លោកនាយករង បានមានប្រសាសន៍ថាកិច្ចប្រជុំនៅថ្ងៃនេះធ្វើឡើងក្នុងគោលបំណងពង្រឹងសេវា នៃការផ្តល់តាវកាលិកហានិភ័យការងារជូនកម្មករនិយោជិត ធ្វើការផ្សព្វផ្សាយគោលនយោបាយថ្មីៗ និងវឌ្ឍនភាពរបស់ ប.ស.ស ។ គ្រោះថ្នាក់ការងារ គឺគ្រោះថ្នាក់ដែលកើតឡើងនៅពេលកម្មករកំពុងធ្វើការ នៅរោងចក្រ សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន និងគ្រោះថ្នាក់ពេលកម្មករទៅ និងត្រឡប់មកពីធ្វើការ។

ជាពិសេសមានមន្ទីរពេទ្យ មណ្ឌលសុខភាព ចុះកិច្ចព្រមព្រៀងក្នុងការផ្តល់សេវាចំនួន៨៥ ផងដែរ។ តាវកាលិក (អត្ថប្រយោជន៍) ដែលសហគ្រាស គ្រឹះស្ថាន និងសមាជិក (កម្មករនិយោជិត) អាចទទួលបានពី ប.ស.ស រួមមាន៖ ការសង្គ្រោះបន្ទាន់ការថែទាំ និងព្យាបាលការទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ ការទទួលបានប្រាក់ធនលាភ និងប្រាក់វិភាជន៍សោហ៊ុយបូជាសព តាវកាលិកឧត្តរជីវី សេវាបុននីតិសម្បទា និងការសម្របសម្រួលវិជ្ជាជីវៈឡើងវិញ។

និយាយជារួម កិច្ចប្រជុំនាថ្ងៃនេះផ្តោតគោលបំណងពង្រឹងសេវានៃការផ្តល់តាវកាលិកហានិភ័យការងារ ជូនកម្មករនិយោជិត ធ្វើការផ្សព្វផ្សាយ គោលនយោបាយថ្មីៗ និងវឌ្ឍនភាពរបស់ ប.ស.ស និងធ្វើការចូលរួមពិភាក្សាពីគ្រប់ភាគី (សហគ្រាស គ្រឹះស្ថាន សាខា ប.ស.ស មន្ទីរពេទ្យចុះកិច្ចព្រមព្រៀង ធនាគារអេស៊ីលីដា ជនរងគ្រោះថ្នាក់ដោយសារការងារ) ៕



សិក្ខាកាមដែលជាតំណាងសហគ្រាស គ្រឹះស្ថានចូលរួមក្នុងអង្គពិធី

# ឆ្លងចរន្តអគ្គិសនីចេញពីម៉ាស៊ីនកំដៅស្បែកជើង បង្កឱ្យកម្មករ និយោជិត ៤៤នាក់សន្លប់ នៅរោងចក្រ LONG LEAD ខេត្តកំពង់ឆ្នាំង

នៅរសៀលថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៥ វេលាម៉ោង១៣:០០ នាទីមានករណីឆ្លងចរន្តអគ្គីសនីម៉ាស៊ីនកំដៅស្បែកជើងបណ្តាលឱ្យមានអណ្តាតភ្លើងឆាបឆេះឡើងនៅរោងចក្រ Long Lead ដែលមានទីតាំងស្ថិតនៅ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។ ក្នុងករណីនេះដែរបានបណ្តាលឱ្យកម្មករមួយចំនួនមានការភិតភ័យ



រូបភាពម៉ាស៊ីនកំដៅស្បែកជើងនៅកន្លែងកើតហេតុ



មន្ត្រីប.ស.ស ចុះទៅសម្របសម្រួលនៅមន្ទីរពេទ្យ និងតាមដានស្ថានភាពជំងឺរបស់ជនរងគ្រោះ

ស្លន់ស្លោ ថប់ដង្ហើម ទន់ដៃទន់ជើងបង្កឱ្យសន្លប់ជាបន្តបន្ទាប់រហូត ដល់៤៤នាក់។

ភ្លាមៗនោះមន្ត្រីប.ស.ស ប្រចាំនៅខេត្តកំពង់ឆ្នាំងបានចុះទៅធ្វើការសម្របសម្រួលជាមួយរោងចក្របញ្ជូនជនរងគ្រោះទៅសង្គ្រោះនៅមន្ទីរពេទ្យបង្អែកស្រុកកំពង់ត្រឡាច ចំនួន០២នាក់ ៤២នាក់ផ្សេងទៀតត្រូវបានបញ្ជូនទៅសង្គ្រោះនៅគ្លីនិក តែ វណ្ណា រាល់ការចំណាយលើថ្លៃព្យាបាលជាបន្ទុករបស់ ប.ស.ស ទាំងស្រុង។

ក្រុមការងារបានស្នើសុំឱ្យរោងចក្រធ្វើការកែលំអ ជួសជុលប្រព័ន្ធអគ្គិសនីឡើងវិញ ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសមុននឹងអនុញ្ញាតឱ្យកម្មករចូលធ្វើការជាធម្មតាវិញ៕



ទិដ្ឋភាពជនរងគ្រោះសម្រាកព្យាបាលនៅគ្លីនិក តែ វណ្ណា

# ការចុះអង្កេតករណីកម្មករនិយោជិតសន្លប់ នៅរោងចក្រ យូលី អ៊ីនធើរណេសិណាល (ខេមបូឌា) ហ្គាមិន ខេត្តស្វាយរៀង

ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ បានចុះអង្កេតករណីកម្មករនិយោជិតសន្លប់ចំនួន ៦៣នាក់ នៅរោងចក្រ យូលី អ៊ីនធើរណេសិណាល (ខេមបូឌា) ហ្គាមិន កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៥ ដែលមានទីតាំងស្ថិតនៅសង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង ក្រោមការដឹកនាំដោយឯកឧត្តមវេជ្ជ. ប៉ុក វណ្ណថាត ប្រធានក្រុមការងារ ទ.ស.ប.ក និង



ក្រុមការងារប្រជុំពិភាក្សារកមូលដែលកើតមានករណីសន្លប់លើកម្មករនិយោជិត

សមាជិកក្រុមការងារជាច្រើនរូប។

ឆ្លងតាមការពិនិត្យអង្កេតទាំងក្នុង និងក្រៅរោងចក្រ និងជួបប្រជុំរួមគ្នារួចមក ក្រុមការងារ ទ.ស.ប.ក សង្កេតឃើញថាករណីកម្មការិនីសន្លប់ទាំង ៦៣នាក់ខាងលើនេះ គឺផ្តើមចេញពីកម្មការិនី ០១ នាក់សន្លប់ ហើយអ្នកផ្សេងឃើញក៏ភិតភ័យសន្លប់តៗគ្នា។ ដោយទ្បែកបរិយាកាសក្នុងអាគារផលិតកម្ម មានបញ្ហាខ្វះខាតមួយចំនួន ដូចជាបង្គន់ខ្វះអនាម័យ គ្មានខ្យល់ចេញចូល និងពន្លឺបំភ្លឺមិនគ្រប់គ្រាន់។



ក្រុមការងារចុះអង្កេតផ្ទាល់នៅកន្លែងកើតហេតុ

ករណីសន្លប់ខាងលើបណ្តាលមកពី មានកម្មការិនី ឈ្មោះ ទេព រី អាយុ ៣០ឆ្នាំ មានអាការៈ ថប់ដង្ហើម ឈឺក្បាល វិលមុខ ទន់ដៃទន់ជើង ត្រូវបានបញ្ជូនទៅសង្គ្រោះនៅគិលានដ្ឋាន ភ្លាមៗនោះគ្រូពេទ្យ និងរដ្ឋបាលរោងចក្របានបញ្ជូនបន្តទៅសង្គ្រោះនៅមន្ទីរពេទ្យបង្អែកជីភូ។ ក្រោយមកមានកម្មការិនីផ្សេងៗទៀតបានទន់ដៃទន់ជើងសន្លប់ជាបន្តបន្ទាប់រហូតដល់ទៅចំនួន ៦៣នាក់។ នៅក្នុងករណីនេះ រោងចក្របានសហការជាមួយអាជ្ញាធរ មន្ទីរ



ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងប.ស.ស ខេត្ត បានបញ្ជូនជនរងគ្រោះទៅពិនិត្យព្យាបាលនៅមន្ទីរពេទ្យបង្អែកជីភូថែមទៀត។

ចំពោះករណីកម្មករនិយោជិតសន្លប់នេះ ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ បានដាក់វិធានការឱ្យរោងចក្រត្រូវធ្វើការកែលំអនូវចំណុចមួយចំនួនដូចជា៖ ត្រូវបើកកង្ហារកន្លះម៉ោងមុនពេលកម្មករចូលធ្វើការ, សំអាតអាគារផលិតកម្ម និងបើកបង្អួចឱ្យអស់ ដើម្បីឱ្យមានខ្យល់ចេញចូលគ្រប់គ្រាន់, និងបានអនុញ្ញាតឱ្យកម្មករនិយោជិតទាំងអស់ចូលធ្វើការវិញ នៅថ្ងៃច័ន្ទទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ក្រោមការឃ្លាំមើលពីគ្រូពេទ្យប្រចាំរោងចក្រ មន្ត្រីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ត្រីប.ស.ស ខេត្តស្វាយរៀង៕

# មនុស្ស ៤នាក់រងរបួស ដោយគ្រោះថ្នាក់ចរាចរណ៍ ដែលបង្ករឡើង រវាងម៉ូតូបុកជាមួយម៉ូតូ នៅខេត្តកំពង់ឆ្នាំង






ស្ថានភាពជនរងគ្រោះក្នុងឧបទ្ទវហេតុ ដោយគ្រោះថ្នាក់ចរាចរណ៍

ករណីគ្រោះថ្នាក់ចរាចរណ៍មួយបានកើតឡើង នៅវេលាម៉ោង ១៦:១៥ នាទីរសៀល ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ នៅចន្លោះគីឡូម៉ែតលេខ៤៦-៤៧ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលបង្ករឡើងរវាងម៉ូតូបុកជាមួយម៉ូតូ បណ្តាលឱ្យរងរបួសទាំងសងខាងរហូតដល់ទៅ៤នាក់។

ជនរងគ្រោះទាំង៤នាក់នេះ មានឈ្មោះ សោម ចាន់ទី ភេទស្រី អាយុ១៨ឆ្នាំ និងឈ្មោះ សោម ចិន្តា ភេទស្រី អាយុ ២០ឆ្នាំ បម្រើការងារនៅរោងចក្រ Long Lead (Cambodia) មានទីតាំងស្ថិតនៅស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ឈ្មោះ អែម សាមាន ភេទប្រុស អាយុ២៦ឆ្នាំ និងឈ្មោះ សោម ជា ភេទប្រុស អាយុ២៨ឆ្នាំ បម្រើការងារនៅរោងចក្រ Tak Fook (Cambodia) មានទីតាំងស្ថិតនៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។

ភ្លាមៗនោះមន្ត្រី ប.ស.ស ខេត្ត បានចុះទៅជួយសម្របសម្រួល និងបញ្ជូនជនរងគ្រោះទាំង៤នាក់ទៅព្យាបាលនៅគ្លីនិក តែ វណ្ណា តែដោយសារស្ថានភាពរបស់ជនរងគ្រោះឈ្មោះ សោម ជា មានសភាពធ្ងន់ធ្ងរពេក ទើបគ្លីនិកបញ្ជូនជនរងគ្រោះបន្តមកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត។ ចំពោះការចំណាយទៅលើមធ្យោបាយដឹកជញ្ជូន និងសេវាព្យាបាលជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។






# កម្មការិនីពនាក់សន្លប់ បង្ករធ្វើឱ្យកម្មការិនីផ្សេងទៀតមានការភិតភ័យ សន្លប់តៗគ្នារហូតដល់៦៩នាក់

ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ (ទ.ស.ប.ក) បានចុះអង្កេតករណីកម្មការិនីសន្លប់ចំនួន ៦៩នាក់ កាលពីរសៀលថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៥ នៅរោងចក្រអ៊ីអ៊ិនស៍ (ខេបូឌា) ខូអិលធីឌី EINS (Cambodia) Co.,LTD ស្ថិតនៅសង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។



ក្រុមការងារប្រជុំរកមូលហេតុនៃការសន្លប់របស់កម្មករនិយោជិត

ករណីសន្លប់នេះក្រុមការងារបានធ្វើការពិនិត្យអង្កេតទាំងក្នុង និងក្រៅរោងចក្រ និងជួបប្រជុំជាមួយនិយោជក សហជីព គិលានុប្បដ្ឋាយិកា និងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទាញរកមូលហេតុដែលនាំឱ្យកើតបញ្ហា និងធ្វើការសម្របសម្រួលដឹកជញ្ជូនកម្មករសន្លប់ចំនួន ៦៩នាក់ ទៅសង្គ្រោះនៅតាមមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុត។ ដោយឡែកកម្មករផ្សេងៗទៀតអនុញ្ញាតឱ្យឈប់សម្រាក។

ក្រោយពីបានប្រជុំពិភាក្សាពិនិត្យឃើញថា មូលហេតុកម្មករសន្លប់ គឺផ្តើមចេញពីកម្មការិនីចំនួន ៣នាក់ មានអារៈឈឺក្បាលវិលមុខអស់កម្លាំង ត្រជាក់ចុងដៃចុងជើង។ រដ្ឋបាលរោងចក្របានបញ្ជូនទៅគ្លីនិកមូលមិត្ត ឃើញដូចនេះបណ្តាលឱ្យកម្មករដទៃទៀតមានការភិតភ័យ ទន់ដៃទន់ជើងសន្លប់តៗគ្នា រហូតដល់ទៅ ៦៩នាក់តែម្តង។ រាល់ការចំណាយលើសេវាដឹកជញ្ជូន និងសេវាព្យាបាលផ្សេងៗជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។ ជាមួយគ្នានេះក្រុមការងារបានដាក់ចេញនូវវិធានការ ដល់និយោជកឱ្យធ្វើការកែលំអចំណុចមួយចំនួនដូចជា៖ ត្រូវបើកប្រព័ន្ធខ្យល់ត្រជាក់ឱ្យបាន៣០នាទី មុនពេលកម្មករ-កម្មការិនីចូលធ្វើការ និងត្រួតពិនិត្យប្រព័ន្ធខ្យល់ត្រជាក់ជាប្រចាំ, គ្រូពេទ្យប្រចាំការគិលានដ្ឋានរោងចក្រ ត្រូវនៅប្រចាំការធ្វើការពិនិត្យព្យាបាលសុខភាពកម្មករនិយោជិតក្នុងម៉ោងធ្វើការ និងអប់រំអំពីសុខភាពកម្មករនិយោជិតស្តីពីរបបចំណីអាហារឱ្យបានត្រឹមត្រូវ។ ចំពោះកម្មករ-កម្មការិនី ដែលមិនមានករណីសន្លប់អនុញ្ញាតឱ្យចូលធ្វើការវិញ នៅថ្ងៃច័ន្ទទី២ ខែមីនា ឆ្នាំ២០១៥។ ចំណែកកម្មករ-កម្មការិនីមានករណីសន្លប់អនុញ្ញាតឱ្យចូលធ្វើការវិញ នៅថ្ងៃព្រហស្បតិ៍ទី៥ ខែមីនា ឆ្នាំ២០១៥។

ស្របជាមួយគ្នានេះក្រុមការងារបាននឹងកំពុងធ្វើការសហការជាមួយនិយោជក ក្នុងការរៀបចំផ្សព្វផ្សាយអប់រំនៅនឹងកន្លែងការងាររបស់រោងចក្រ ដល់កម្មករនិយោជិតអំពីលក្ខខណ្ឌអនាម័យសុវត្ថិភាពការងារ លក្ខខណ្ឌការងារ អត្ថប្រយោជន៍របបសន្តិសុខសង្គម និងសុវត្ថិភាពចរាចរណ៍របស់កម្មករនិយោជិត៕



កិច្ចពិភាក្សារកមូលហេតុដែលនាំឱ្យកម្មករសន្លប់



# ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក ចុះផ្សព្វផ្សាយអប់រំអំពីច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក នៅខេត្តកណ្តាល

កាលពីព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានចុះផ្សព្វផ្សាយអប់រំអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងបានពន្យល់ណែនាំពីការធ្វើដំណើរប្រកបដោយសុវត្ថិភាព។

កិច្ចប្រជុំផ្សព្វផ្សាយអប់រំនេះធ្វើឡើងដើម្បីចូលរួមកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ឱ្យនៅកម្រិតទាប។ ដែលដឹកនាំដោយលោកស្រី បុប្ផា ជានី អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ ជាសមាជិកក្រុមការងារ ស.ផ.គ និងលោក ជាវ ប៊ុនរិទ្ធ សមាជិកក្រុមការងារ ព្រមទាំងសិក្ខាកាមចូលរួមដែលជាអ្នកបើកបរដឹកកម្មករនិយោជិតជាច្រើនរូបទៀត។

គោលបំណងនៃការផ្សព្វផ្សាយនេះ គឺណែនាំពីការធ្វើដំណើរប្រកបដោយសុវត្ថិភាព ដល់កម្មករនិយោជិត ជាពិសេសជំរុញឱ្យអ្នកបើកបរទាំងអស់ ត្រូវទៅរៀននៅសាលាបង្រៀនបើកបរ ឱ្យបានត្រឹមត្រូវ ប្រឡងយកប័ណ្ណបើកបរ ត្រូវមានការយល់ដឹង នឹងត្រូវត្រួតពិនិត្យយានយន្ត ជាប្រចាំរៀងរាល់ថ្ងៃមុនពេលចេញដំណើរ ចំពោះកម្មករនិយោជិតត្រូវគោរពច្បាប់ចរាចរណ៍ត្រូវពាក់មួកសុវត្ថិភាពឱ្យបានត្រឹមត្រូវដើម្បីការពារអាយុជីវិត។

ខណៈនោះដែរ គ្រូឧទ្ទេសនាម ក៏បានពន្យល់ណែនាំពីគុណសម្បត្តិ នៃការពាក់មួកសុវត្ថិភាព និងគុណវិបត្តិ ដែលប៉ះពាល់ដល់ជនរងគ្រោះនៃការមិនពាក់មួកសុវត្ថិភាព។

ក្នុងឱកាសនោះ លោក ជាវ ប៊ុនរិទ្ធ ប្រធានការិយាល័យគោលនយោបាយ បានធ្វើបទឧទ្ទេសនាម ពីគោលនយោបាយរបស់ ប.ស.ស ដែលបច្ចុប្បន្ននេះ កំពុងធានារ៉ាប់រងគ្រោះថ្នាក់ការងារ ដល់កម្មករនិយោជិត ដែលទទួលរងគ្រោះថ្នាក់ ដោយការងារ និងគ្រោះថ្នាក់ពេលទៅ និងត្រឡប់មកពីធ្វើការវិញ។

លោក ជាវ ប៊ុនរិទ្ធ បានពន្យល់បន្ថែមពីអត្ថប្រយោជន៍ នៃតាវកាលិក (អត្ថប្រយោជន៍) ដែលសហគ្រាស គ្រឹះស្ថាន និងសមាជិក (កម្មករនិយោជិត) នឹងទទួលបានពីប.ស.ស រួមមាន៖ ការសង្គ្រោះបន្ទាន់, ការថែទាំ និងព្យាបាល, ការទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ,ការទទួលបានប្រាក់ធនលាភ និងប្រាក់វិភាជន៍, សោហ៊ុយបូជាសព, តាវកាលិកឧត្តរជីវី សេវាបុនទីតិសម្បទា និងការសម្របសម្រួលវិជ្ជាជីវៈឡើងវិញ នៅក្រុមហ៊ុន 7NG Group CO.,LTD ខេត្តកណ្តាល៕







ក្រុមការងារ ចូលរួមជាអធិបតី និងសិក្ខាកាមចូលរួមក្នុងអង្គពិធី

## តាវភាលិក (អត្ថប្រយោជន៍) ហានិភ័យការងារ

សេវាសង្គ្រោះបន្ទាន់



សេវាបុនរ្នីតិសម្បទា



ការថែទាំ និងព្យាបាល












ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃ



តាវកាលិកសម្រាប់អ្នកចាំថែរក្សាជនរងគ្រោះ



ការផ្តល់វិភាជន៍ និងប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ក្រោម២០% និង២០%ឡើង





ការផ្តល់ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព




តាវកាលិកឧត្តរជីវីសម្រាប់អ្នករស់នៅក្នុងបន្ទុក នៃជនរងគ្រោះ



## កិច្ចដំណើរការ និងដំណើរឆ្ពោះទៅមុខរបស់ ប.ស.ស

១- ផ្នែកហានិភ័យការងារ

- ផ្តល់ការព្យាបាល
- ផ្តល់ឧបករណ៍អវៈយវៈសិប្បនិម្មិត
- ផ្តល់ប្រាក់ឧបត្ថម្ភផ្សេងៗ

២- ផ្នែកថែទាំសុខភាព

ប.ស.ស បង្កើតឱ្យមានរបបនេះ គឺដើម្បីផ្តល់នូវការថែទាំ និងព្យាបាលជំងឺផ្សេងៗ ដល់សមាជិករបស់ខ្លួន ដែលនឹងចាប់ដំណើរការនៅក្នុងឆ្នាំ២០១៥

៣- ផ្នែកប្រាក់សោធន (ប្រាក់ចូលនិវត្តន៍)

កម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់សោធន ដូចមន្ត្រីរាជការដែរ ដែលនឹងចាប់ផ្តើមដំណើរការនៅឆ្នាំ២០១៦ ។

## តើពេលគ្រោះថ្នាក់ការងារត្រូវធ្វើដូចម្តេច?

១- កម្មករនិយោជិត ត្រូវជូនដំណឹងទៅនិយោជក ឬក្នុងករណីសង្គ្រោះបន្ទាន់អាចទំនាក់ទំនងផ្ទាល់មក ប.ស.ស តាមរយៈប្រព័ន្ធទូរស័ព្ទទំនាក់ទំនង Hot-Line **១២៨៦**

២- និយោជក ឬម្ចាស់សហគ្រាស ត្រូវជូនដំណឹងមកបេឡាជាតិរបបសន្តិសុខសង្គមក្នុងរយៈពេលយ៉ាងយូរបំផុត ៤៨ ម៉ោង នៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលដំណឹងពីជនរងគ្រោះ

៣- ការជូនដំណឹងហានិភ័យការងារជាបឋម អាចធ្វើតាមរយៈសារអេឡិចត្រូនិច (Email: benefit@nssf.gov.kh) បន្ទាប់មកត្រូវធ្វើទម្រង់របាយការណ៍ហានិភ័យការងារបញ្ជូនមក ប.ស.ស ផ្ទាល់។

# បេឡាជាតិរបបសន្តិសុខសង្គម
(ប.ស.ស)



## ធានាសន្តិសុខប្រាក់ចំណូល
## រួមចំណែកកាត់បន្ថយភាពក្រីក្រ
## លើកកម្ពស់សុខុមាលភាពសង្គម


ទូរស័ព្ទលេខ៖ ០២៣ ៨៨២ ៦២៣ / ៨៨២ ៤៣៤
ទូរសារ៖ ០២៣ ៨៨២ ៦២៣
ទូរស័ព្ទទំនាក់ទំនងបន្ទាន់ (Hot-Line)៖ ១២៨៦
គេហទំព័រ៖ www.nssf.gov.kh
សារអេឡិចត្រូនិច៖ info@nssf.gov.kh /benefit@nssf.gov.kh

# សារសំខាន់នៃការចុះសំបុត្រអាពាហ៍ពិពាហ៍ របស់កម្មករនិយោជិត

ទឹកប្រាក់ចំនួន៤លានរៀល និងប្រាក់ឧបត្ថម្ភផ្សេងៗទៀត ត្រូវបានប្រគល់ជូនអ្នកនៅក្នុងបន្ទុកផ្ទាល់នៃជនរងគ្រោះ នៅពេលដែលជនរងគ្រោះ(កម្មករនិយោជិត)ទទួលរងគ្រោះថ្នាក់រហូតដល់បាត់បង់ជីវិត។

ដើម្បីឱ្យអ្នកនៅក្នុងបន្ទុកផ្ទាល់ នៃជនរងគ្រោះ ទទួលបានអត្ថប្រយោជន៍ពីប.ស.ស កម្មករនិយោជិត ដែលរៀបការរួចហើយ ត្រូវទៅចុះសំបុត្រអាពាហ៍ពិពាហ៍ឱ្យបានគ្រប់ៗគ្នា ។ នេះជាកត្តាសំខាន់បំផុតសម្រាប់កម្មករនិយោជិត នៅពេលដែលខ្លួនទទួលរងហានិភ័យការងាររហូតដល់បាត់បង់ជីវិត។

យោងតាមអនុក្រឹត្យលេខ១៦អនក្រ/បក ចុះថ្ងៃទី០២ខែមិនា ឆ្នាំ២០០៧, ប្រកាស លេខ ១០៩ កប/ប្រកចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ,និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស ប.ស.ស បានសម្រេចផ្តល់វិភាជន៍ជាសោហ៊ុយបូជាសពចំនួន៤,០០០,០០០(បួនលានរៀល) និងអត្ថប្រយោជន៍ ផ្សេងៗទៀតដូចជា (ការឧបត្ថម្ភដល់ប្តី/ប្រពន្ធ កូន ឪពុក ម្តាយ ឬជនចាស់ជរា នៅក្នុងបន្ទុកផ្ទាល់ នៃជនរងគ្រោះដែលទទួលរងហានិភ័យការងាររហូតដល់បាត់បង់ជីវិត។ អ្នកនៅក្នុងបន្ទុកផ្ទាល់មានសិទ្ធិទទួលអត្ថប្រយោជន៍បាន លុះត្រាតែ កម្មករនិយោជិតដែលរៀបការរួចហើយត្រូវ ចុះបញ្ជីអត្រានុកូលដ្ឋានក្នុង នោះមាន(***ចុះសំបុត្រអាពាហ៍ពិពាហ៍..***)ឱ្យបានគ្រប់ៗគ្នា។

ដូចកម្មករនិយោជិតបានជ្រាបហើយថា ការរៀបការត្រូវបានចំណាយប្រាក់កាសជាច្រើនក៏ពិតមែន ប៉ុន្តែបើយើងមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ គឺមង្គលការនោះពិតជាគ្មានន័យអ្វីឡើយ ដោយសារច្បាប់ពុំទទួលស្គាល់។

ផ្ទុយទៅវិញ បើយើងបានរៀបការរួចហើយក្តី មិនបានរៀបការតាមប្រពៃណី ឬគ្រាន់តែជាការសែនព្រេនក្តី ឬស្មោះស្ម័គ្រស្រឡាញ់គ្នាប្រការណាមួយក្តី...។ ប៉ុន្តែបើយើងនាំគ្នាទៅចុះសំបុត្រអាពាហ៍ពិពាហ៍ នោះនឹងត្រូវបានច្បាប់ទទួលស្គាល់ជាផ្លូវការ។ រីឯការចំណាយលុយកាក់សម្រាប់***ការចុះសំបុត្រអាពាហ៍ពិពាហ៍ចំណាយប្រាក់តែបន្តិចបន្តួចតែប៉ុណ្ណោះ។***

ប.ស.ស នឹងផ្តល់អត្ថប្រយោជន៍ផ្សេងៗដល់អ្នកនៅក្នុងបន្ទុកផ្ទាល់ នៃជនរងគ្រោះតាមផ្លូវច្បាប់ ប្រសិនបើជនរងគ្រោះដែលជាកម្មករនិយោជិតបានចុះសំបុត្រអាពាហ៍ពិពាហ៍។

ប.ស.ស សូមអំពាវនាវដល់ បង ប្អូនកម្មករនិយោជិតទាំងអស់មេត្តាជ្រាបថា បើបង ប្អូនបានរៀបការរួច សូមមេត្តានាំគ្នាទៅចុះសំបុត្រអាពាហ៍ពិពាហ៍ឱ្យបានគ្រប់ៗគ្នា ដើម្បីឱ្យអ្នកដែលនៅក្នុងបន្ទុកផ្ទាល់ទទួលបានអត្ថប្រយោជន៍ពីប.ស.ស នៅពេលដែលខ្លួនទទួលរងគ្រោះថ្នាក់ដោយសាការងាររហូតបណ្តាលឱ្យបាត់បង់ដល់ជីវិត។

# ដំណោះស្រាយដើម្បីបញ្ចៀស និងទប់ស្កាត់ ពេលកើតឡើងនូវឧប្បទវហេតុក្នុងកន្លែងធ្វើការ

ដើម្បីជៀសវាងកុំឱ្យកម្មករផ្សេងៗទៀតមានការជ្រួលសន្លប់តៗគ្នាជាច្រើនដែរនោះ កម្មករនិយោជិតត្រូវជួយគ្នាដើម្បីអនុវត្តដូចខាងក្រោម៖

- បញ្ជូនជនរងគ្រោះទៅកន្លែងជិតបំផុត *(ករណីសង្គ្រោះបន្ទាន់)* បន្ទាប់មកត្រូវបញ្ជូនទៅមន្ទីរពេទ្យ ដែលទទួលស្គាល់ដោយប.ស.ស។
- ផ្តល់យោបល់ដល់គ្រូពេទ្យត្រូវផ្តល់ការលើកទឹកចិត្តដល់អ្នកជម្ងឺ ដើម្បីកុំឱ្យអ្នកជម្ងឺមានការភ័យខ្លាចតទៅទៀត
- ជម្លៀសមនុស្សចេញពីកន្លែងកើតហេតុឱ្យបានឆាប់
- ជម្លៀសអ្នកផ្សេងឱ្យជៀសឆ្ងាយពីតំបន់ដែលកើតហេតុ ឬតំបន់ដែលមានការជ្រួលច្របល់ខ្លាំង ឬមានសម្ពាធខ្លាំងជាដើម។
- បំបែកក្រុមមនុស្សដែលមានមនុស្សច្រើន ឱ្យនៅតិចបំផុត
- បំបែកក្រុមមនុស្សដែលមានជម្ងឺ និងមនុស្សដែលគ្មានជម្ងឺឱ្យនៅដាច់ឆ្ងាយពីគ្នា។
- ណែនាំកម្មករ(អ្នកជម្ងឺ)ឱ្យមានជំនឿទុកចិត្តថា កន្លែងធ្វើការមានសុវត្ថិភាពល្អឡើងវិញ ជៀសវាងការមិនទុកចិត្តប្រការណាមួយនាំឱ្យមានការសង្ស័យ និងភ័យខ្លាចបន្តទៀត។
- ថែទាំអ្នកជម្ងឺម្នាក់ៗដោយមានការពិនិត្យពិច័យឱ្យបានល្អិតល្អន់ពីគ្រូពេទ្យជំនាញ
- អ្នកជំនាញ ត្រូវត្រួតពិនិត្យបរិយាកាសក្នុង ឬជុំវិញកន្លែងធ្វើការឱ្យបានហ្មត់ចត់
- ទុកដាក់សារធាតុគីមីនិងសម្ភារៈផ្សេងៗទៀតឱ្យមានសុវត្ថិភាព និងទៅតាមលក្ខណៈបច្ចេកទេស។

**សេចក្តីបញ្ជាក់:** ការអនុតវត្តការងារប្រកបដោយប្រសិទ្ធភាពទៅបាន ទាល់តែមានការសហការយ៉ាងស្អិតរមួត និងមានការទទួលខុសត្រូវខ្ពស់ពីសំណាក់បង ប្អូនកម្មករនិយោជិតផងដែរ។

**លក្ខណ្ឌការងារល្អ សុខភាពកម្មករនិយោជិតល្អ ផលិតកម្មល្អ**

# អ្នកដំណើរផ្ញើជីវិតលើអ្នកបើកបរ

យើងដឹងហើយថា គ្រោះថ្នាក់ចរាចរណ៍ជាឃាតករលាក់មុខ ដែលបញ្ហានេះធ្វើឱ្យមនុស្សរាប់សិបនាក់ទទួលរងរបួស និងស្លាប់ដោយមិនដឹងខ្លួនយ៉ាងអាណោចអាធ៌មបំផុត ដោយសារអ្នកបើកបរតែម្នាក់ឯងប៉ុណ្ណោះ។

រយៈពេលកន្លងមកនេះ គ្រោះថ្នាក់បានកើតឡើងជាច្រើនករណី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងនោះក៏មានកម្មករនិយោជិតជាច្រើនផងដែរ ដែលទទួលរងដោយសារឧប្បទវហេតុនេះ។

ដោយឡែក បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានកំណត់ថា នេះជាគ្រោះថ្នាក់ការងារ ដែលប.ស.ស ត្រូវទទួលខុសត្រូវទាំងស្រុង។ គ្រោះថ្នាក់ការងារនេះគឺ កើតឡើងនៅពេលដែលកម្មករនិយោជិតធ្វើដំណើរពីកន្លែងធ្វើការទៅផ្ទះ និងពីផ្ទះមកកន្លែងធ្វើការដោយត្រង់ និងមិនវៀងទៅណាផ្សេងជាបំណងផ្ទាល់ខ្លួន។

ដូចដែលយើងបានជ្រាបច្បាស់ហើយថា ការទទួលរងគ្រោះថ្នាក់រមែងតែងតែបាត់បង់នូវផលប្រយោជន៍ជាច្រើន ទាំងពេលវេលា ទាំងសម្ភារៈ ទាំងប្រាក់កាស និងអាចប៉ះពាល់ដល់អាយុជីវិតទៀតផង។ ជា ពិសេស បញ្ហានេះក៏ធ្លាក់លើអ្នកបើបរខ្លួនឯងផ្ទាល់ផងដែរ។ ម៉្យាងទៀតអ្នក បើកបរក៏មានវិប្បដិសារីដោយទទួល ការសោកស្តាយយ៉ាងខ្លាំងចំពោះបញ្ហានេះកើតឡើង និងមានការទទួលទោសតាមច្បាប់ជាធរមាន។

មួយវិញទៀត អ្នកបើកបរតែម្នាក់ឯង ធ្វើឱ្យអ្នកដំណើររាប់សិបអ្នករងរបួស និងស្លាប់យ៉ាងអាណោចអាធ៌ម ដោយសារការមិនគោរពច្បាប់ចរាចរណ៍ ឬទ្វេសប្រហែសរបស់ខ្លួន តែមួយពព្រិចភ្នែកតែប៉ុណ្ណោះ។

ដូច្នេះ ដើម្បីជៀសវាងកុំឱ្យគ្រោះថ្នាក់នេះកើតឡើងជាយថាហេតុណាមួយនោះ ប.ស.ស សូមអំពាវនាវដល់អ្នកបើកបរទាំងឡាយ ក៏ដូចជាអ្នកបើកបរតាមបណ្តារោងចក្រសហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវ គោរពច្បាប់ចរាចរណ៍ឱ្យបានខ្ជាប់ខ្ជួន ពីព្រោះការគោរពច្បាប់ចរាចរណ៍គឺគោរពជីវិតខ្លួនឯង, បើកបរកុំសេពគ្រឿងស្រវឹង, បើកបរមានការប្រុងប្រយ័ត្នជានិច្ច, និងត្រូវថែរក្សាយានយន្តឱ្យបានជាប្រចាំ។ល។ និង។ល។

ប.ស.ស សង្ឃឹមថា អ្នកបើកបរអនុវត្តតាមការណែនាំ មានប្រសិទ្ធភាពខ្ពស់ និងអាចកាត់បន្ថយករណីនេះឱ្យនៅទាបជាកម្រិតអប្បរមា។

**បើកបរប្រហែសមួយវិនាទី ធ្វើឱ្យទុក្ខសោកមួយជីវិត**

# ច្បាប់ទូន្មានសម្រាប់ជនប្រុសស្រី



អ្នកព្រះភិរម្យភាសារអ៊ូ ជាគ្រូចម្រៀងក្នុងស្រុកខ្មែរ
ប្រដៅពួកក្មេងកូនអ្នកស្រែ កិច្ចកែជាពិរកម្ពីរពិត។
ប្រដៅកូនចៅទាំងប្រុសស្រី កើតមកលើដីឱ្យចេះគិត
ខ្លះមានកំណើតឥតមានគំនិត ខ្លះមានជីវិតឥតប្រប្រាជ្ញ។
បញ្ញត្តិច្បាប់នេះឱ្យបានដឹង ឱ្យខំព្រឹត្តប្រឹងគិតពិចារណា
បំណាច់កើតមកមានពង្សា កុំឱ្យគេថាអាក្រក់បាន។
កិច្ចការគួរសមគិតឱ្យអស់ កុំឱ្យចន្លោះនៅសល់ខាន
របស់ខុសត្រូវទាំងប៉ុន្មាន ព្រឹត្តប្រុងក្នុងប្រាណទើបបានប្រាជ្ញ។
រៀនច្បាប់ឱ្យឆ្អិនកុំឱ្យឆៅ ចិត្តល្អិតក្នុងក្រៅអ្នកខ្លៅខ្លាច
មនុស្សមានចំណេះមានអំណាច ចង់ឈ្នះមនុស្សកាចកុំស្តីកោង។
ស្តីការមុចក្រោយកុំឱ្យភ្លាត់ កុំអាងតែមាត់មានប្រហោង
បើមនុស្សព្រហើនហួសទំនង កុំតោងករទល់កើតខ្វល់ទាស់។
អាដែងមនុស្សពាលពោលមិនពិត កុំយកធ្វើមិត្តខាតរបស់
មនុស្សណាសុចរិតចិត្តសប្បុរស ស្រឡាញ់ឱ្យស្មោះចិត្តឱ្យស្មើ។
កើតមកជាមនុស្សកុំល្ងង់ពេក រៀនស៊ីរៀនដេកហើយរៀនដើរ
រៀនចេះប្រសព្វគាប់ប្រសើរ កុំគ្នានេះក្លើអ្នកដែលមានស័ក។
កុំមានតែរូបនិងដង្ហើម រៀនដេកជាដើមដេកឆាប់ភ្ញាក់
ពូថៅដាវវែងលំពែងផ្គាក់ ទុកដាក់កុំឱ្យឃ្លាតពីខ្លួន។
ទុកហើយស្មៀមស្ងាត់កុំមាត់ករ ក្រែងមនុស្សមិនល្អវាលបពួន
មជ្ឈឹមយាមម៉ោងបី រឺម៉ោងបួន បើដឹងខ្លួនកុំដេកវិញ។

# ផ្លែគីវី ផ្ដល់ប្រយោជន៍ច្រើន ចំពោះរាងកាយ



គីវីពណ៌មាស ជាផ្លែឈើមួយប្រភេទដែលផ្ដល់ប្រយោជន៍ជាច្រើនដល់រាងកាយ មានសារធាតុរ៉ែ និងវីតាមីនច្រើនជាងផ្លែឈើប្រភេទផ្សេងៗ ហើយក្នុងមួយផ្លែមានវីតាមីន C ច្រើនជាងក្រូចដល់៣ដង ច្រើនជាងបរិមាណដែលរាងកាយត្រូវការក្នុង១ថ្ងៃស្មើរតែ២ដង មានប៉ូតាស្យូមស្មើចេក១ផ្លែ ថែមទាំងពោពេញទៅដោយវីតាមីន E ហ្វូលេត និងកាកសរសៃ៕

ការទទួលទានបន្លែ ផ្លែឈើ អាចជួយបំប៉នខ្សែភ្នែកឱ្យរឹងមាំ និងការពារពីជំងឺផ្សេងៗ...។

-ត្រកួន ៖ ជួយបំប៉នខ្សែភ្នែក មិនធ្វើឱ្យឈឺភ្នែក ភ្នែកម្ញូ រលាកភ្នែក ត្រូវទទួលទានត្រកួនឆៅថែមទាំងមានវីតាមីន A និង C រួមទាំងបេតាខារ៉ូទីន ជាវីតាមីន ជួយការពារមហារីកបានផងដែរ។ ក្រៅពីនេះ ត្រកួន មានសារធាតុរ៉ែ ជាតិដែកជួយបំប៉នឈាម។

- ការ៉ុត ៖ មានសារធាតុបេតាខារ៉ូទីនច្រើនបំផុត ថែមទាំងមានវីតាមីន និងសារធាតុរ៉ែច្រើនប្រភេទ។ វីតាមីន A ជួយបំប៉នកែវភ្នែកហើយជួយឱ្យស្បែកស្អាត និងបង្កើនប្រព័ន្ធការពាររាងកាយការពារជំងឺផ្សេងៗ ដូចជាមហារីក។

-ស្លឹកបាស: មានគុណប្រយោជន៍ផ្នែកអាហារខ្ពស់ មានបេតាខារ៉ូទីនល្អបំផុត និងជាសារធាតុក្រុមខារ៉ូទីណយត៍ ធ្វើតួនាទីត្រងពន្លឺឱ្យកែវភ្នែកការពារកញ្ចក់ភ្នែក ពីការការពារកើតជំងឺភ្នែកឡើង។

- ខាត់ណា ៖ មានសារធាតុប្រឆាំងរ៉ាឌីកាល់សេរី គឺវីតាមីន C និងបេតាខារ៉ូទីន ដែលរាងកាយនឹងប្តូរជាវីតាមីន A មានផលចំពោះការបំប៉នខ្សែភ្នែក និងប្រឆាំងការឆ្លងមេរោគ។

- ល្ពៅ ៖ ជួយបំប៉នខ្សែភ្នែក ស្បែក ប្រព័ន្ធរំលាយអាហារ បំប៉នថ្លើម តម្រងនោម បង្កើតកោសិកាថ្មីជំនួសកោសិកាចាស់ ដែលងាប់ មានវីតាមីន A បំប៉នខ្សែភ្នែក និងបេតាខារ៉ូទីន ដែលមានសារធាតុប្រឆាំង រ៉ាឌីកាល់សេរីខ្ពស់ ជួយប្រឆាំងមហារីកបានផងដែរ៕



# ទស្សនគួរពិចារណា


វិទ្យុ Cool FM 100.7
មានពាក្យមួយពោលថា
រស់នៅទៅមកមិនស្គាល់ទីតាំង
វែកនៅក្នុងឆ្នាំងមិនស្គាល់សម្ល
ឆ្មាដេកលើអង្ករមិនស្គាល់បាយ
ស្រីល្អដើរតាមតែមិនស្គាល់ចិត្ត!


ប្រឹងដើរដោយខ្លួនឯង
ព្រោះគ្មានអ្នកណាអាចមក
ដើរកំដរយើងបានមួយជីវិតទេ


គិតហើយមិនធ្វើ
និងធ្វើដោយមិនបានគិត
គឺជាមូលហេតុចម្បង
នៃភាពបរាជ័យ
ice watch


ដាំដើមក្រូចឆ្មារ
កុំស្រមៃចង់បាន
ផ្លែក្រូចថ្លុង


កុំរង់ចាំ
ជាតិក្រោយ
ទើបសងគុណ
អ្នកមានគុណ
អ្នក។
hiya



# ទូរស័ព្ទ: ១២៨៦

# ក្រុមប្រចាំការ Hotline 24 ម៉ោង

ចាប់តាំងពីការដាក់ឱ្យដំណើរការផ្នែកធានារ៉ាប់រងហានិភ័យការងារ (គ្រោះថ្នាក់ការងារ) រហូតមកដល់បច្ចុប្បន្នមានរយៈពេលជិត ៦ឆ្នាំមកហើយ ដោយទទួលបានជោគជ័យគួរជាទៅមោទនៈ។ ទន្ទឹមនឹងភាពជោគជ័យនេះ បេឡាជាតិរបបសន្តិសុខសង្គម បាននឹងកំពុងរៀបចំដាក់ឱ្យដំណើរការផ្នែកធានារ៉ាប់រងសុខភាព ដែលជាជំហានទី ០២ របស់ខ្លួន ដែលគម្រោងនឹងឱ្យដំណើរការនៅឆាប់ៗខាងមុខ និងដើម្បីរួមចំណែកក្នុងការជំរុញឱ្យផ្នែកធានារ៉ាប់រងសុខភាព ទទួលបានជោគជ័យ ដូចផ្នែកធានារ៉ាប់រងហានិភ័យការងារ ក្រុមការងារ HOTLINE ដែលជាផ្នែកមួយដ៏សំខាន់ នៃបេឡាជាតិរបបសន្តិសុខសង្គម បានត្រៀមខ្លួនរួចជាស្រេច ទាំងសមត្ថភាព និងជំនាញក្នុងការបម្រើសេវា ផ្នែកធានារ៉ាប់សុខភាព ដែលនឹងដាក់ឱ្យដំណើរការនាពេលដ៏ឆាប់ខាងមុខនេះ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយលទ្ធផលល្អប្រសើរ។ ភាពជោគជ័យនេះ គឺបានមកដោយសារការខិតខំប្រឹងប្រែង ពីគ្រប់បណ្តាផ្នែកទាំងអស់នៃបេឡាជាតិរបបសន្តិសុខសង្គម។ ក្នុងនោះក៏មានក្រុមការងារ HOTLINE នៃការិយាល័យគោលនយោបាយផងដែរ។

ជាក់ស្តែងក្នុងត្រីមាសទី១ ឆ្នាំ២០១៤ ក្រុមការងារ HOTLINE បានអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម និងទទួលបានលទ្ធផលជាផ្លែផ្កាគួរឱ្យកត់សម្គាល់ និងទទួលព័ត៌មានពីសមាជិក បេឡាជាតិរបបសន្តិសុខសង្គម បានជាច្រើនលើក, ធ្វើការសម្របសម្រួល សម្រាប់សេវាសង្គ្រោះបន្ទាន់បានជាច្រើនដង, ទទួលបានព័ត៌មានករណីសន្លប់បានជាច្រើនករណី, និងធ្វើការសម្របសម្រួលនូវបញ្ហាសមាជិកទទួលរងគ្រោះថ្នាក់រហូតដល់សន្លប់បានមួយចំនួន ដល់ស្លាប់ បានមួយចំនួនទៀត។

ទន្ទឹមនឹងទទួលបានលទ្ធផលជាផ្លែផ្កាក្តី ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែរដែលតម្រូវឱ្យក្រុមការងារ HOTLINE នៅតែខិតខំប្រឹងប្រែងដោះស្រាយរាល់ការប្រឈមនោះ ឱ្យមានភាពរលូន និងរហ័សទាន់ពេលវេលា ដើម្បីបម្រើសេវាសាធារណៈ ជូនដល់សមាជិកនៃបេឡាជាតិរបបសន្តិសុខសង្គម ឱ្យបានល្អបន្ថែមទៀត៕



សកម្មភាពទំនាក់ទំនងការងារ របស់អតិថិជនជាមួយក្រុមការងារ HotLine

# អាសយដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង សាខា ប.ស.ស តាមបណ្តារាជធានី-ខេត្ត

### ទីស្នាក់ការកណ្តាល ប.ស.ស រាជធានីភ្នំពេញ

អាសយដ្ឋាន: អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ៨៨២ ៩៣៤, ០២៣ ៩៩៨ ៩១៧
០២៣ ៩៩៨ ៩១៨, ០២៣ ៩៩៨ ៩១៩
ទូរសារ: ០២៣ ៨៨២ ៦២៣
គេហទំព័រ: www.nssf.gov.kh

### សាខា ប.ស.ស ខេត្តសៀមរាប

អាសយដ្ឋាន: ផ្ទះលេខP១០ ភូមិត្រពាំងសេះ ឃុំគោកចក ក្រុងសៀមរាប ខេត្តសៀមរាប
ទូរស័ព្ទដៃ: ០១២ ៥៣៤ ៣៩៥, ០៧៧ ៦៦៣ ២១៧
ទូរស័ព្ទ: ០៦៣ ៩៦៥ ៩៣៤
គេហទំព័រ: www.nssf.gov.kh
E-mail: pang_sokchea@yahoo.com

### សាខា ប.ស.ស ខេត្តកណ្តាល

អាសយដ្ឋាន: ផ្ទះលេខ០១ ផ្លូវលេខ២០២ ភូមិដើមមៀន សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល
ភូមិក្នុង ផ្លូវផ្សារព្រែកតាមាក់ ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល
ទូរស័ព្ទ: ០២៤ ៦៩០ ១៦៧៦, ០៧៧ ៩៦៣ ០៧៨
E-mail: kandal_@nssf.gov.kh

### សាខា ប.ស.ស ខេត្តបន្ទាយមានជ័យ

អាសយដ្ឋាន: ភូមិគីឡូម៉ែតលេខ៤ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
ភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ
ទូរស័ព្ទ: ០៥៤ ៧១១ ៩៩១, ០៧៧ ៦៦៣ ២១៨
E-mail: nssf_bmc@nssf.gov.kh

### សាខា ប.ស.ស ខេត្តកំពង់ស្ពឺ

អាសយដ្ឋាន: ផ្ទះលេខ៣៦A ភូមិស្វាយជ្រុំ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ: ០២៤ ៦៨៨ ០០៩៧, ០៧៧ ៥៧០ ៩០៧
E-mail: nssf_ksp@nssf.gov.kh
movratha@nssf.gov.kh

### សាខា ប.ស.ស ខេត្តកំពង់ចាម

អាសយដ្ឋាន: ផ្លូវជាតិលេខ៧ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម
ទូរស័ព្ទ: ០៤២ ៦៥២ ១៩៩៩, ០៧៧ ៩៩០ ០៤៨
E-mail: nssf_kpc@nssf.gov.kh
say.sothon@nssf.gov.kh

### សាខា ប.ស.ស ខេត្តព្រះសីហនុ

អាសយដ្ឋាន: សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
ទូរស័ព្ទ: ០៣៤ ៩៣៤ ៦០៦, ០៧៧ ៦៦៣ ២១៥
E-mail: nssf_shv@nssf.gov.kh
tong_samnieng@nssf.gov.kh

### សាខា ប.ស.ស ខេត្តកំពង់ធំ

អាសយដ្ឋាន: ភូមិទី៧, សង្កាត់កំពង់ធំ, ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
ទូរស័ព្ទ: ០៦២ ២១០ ៩៦៣, ០៩២ ៧៩៧ ០៩៩
E-mail: kp_thom@nssf.gov.kh
ly_sokha2007@yahoo.com

### សាខា ប.ស.ស ខេត្តស្វាយរៀង

អាសយដ្ឋាន: ផ្លូវជាតិលេខ១ ភូមិបាវិតលើ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង
ទូរស័ព្ទ: ០៩៩ ៧១៥ ៨៣១, ០៧៧ ៦៦៣ ២១៤
E-mail: pek.samol@nssf.gov.kh

### សាខា ប.ស.ស ខេត្តព្រៃវែង

អាសយដ្ឋាន: ផ្ទះលេខ១០៧ ភូមិលេខ៣ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង
ទូរស័ព្ទ: ០៩២ ៧០៨ ៨០៣, ០១២ ៥៩៨ ៨០៥
E-mail: preyveng@nssf.gov.kh
reythearith@yahoo.com

### សាខា ប.ស.ស ខេត្តកំពង់ឆ្នាំង

អាសយដ្ឋាន: ផ្ទះលេខC495 ភូមិម៉ុងបារាំង សង្កាត់ប្អេរ ក្រុមទី១៨ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
ទូរស័ព្ទ: ០២៦ ៧៧៥ ៥៦៦, ០៧៧ ៦៦៣ ២១៦
E-mail: nssf_kcn@nssf.gov.kh

### សាខា ប.ស.ស ខេត្តក្រចេះ

អាសយដ្ឋាន: ភូមិរកាកណ្តាលទី១ សង្កាត់រកាកណ្តាល ក្រុងក្រចេះ ខេត្តក្រចេះ
ទូរស័ព្ទ: ០៩២ ៨៧៣ ០៥១, ០៧៧ ៥៧០ ៩០៤
E-mail: kratie@nssf.gov.kh
soksay.he@nssf.gov.kh

**សាខា ប.ស.ស ខេត្តកំពត**

អាសយដ្ឋាន: ភូមិ១ឧសភា ឃុំកំពង់កណ្តាល ស្រុកកំពង់បាយ ក្រុងកំពត ខេត្តកំពត

ទូរស័ព្ទ: ០៣៣ ៩៣២ ១៣៣, ០១២ ៦២៣ ៣៣២

E-mail: kompot@nssf.gov.kh

phakchetra@gmial.com

**សាខា ប.ស.ស ខេត្តពោធិ៍សាត់**

អាសយដ្ឋាន: ផ្ទះលេខ០០៧ ភូមិរ៉ា សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

ទូរស័ព្ទ: ០៥២ ៩៥១ ១២៣, ០៩២ ៧០៧ ៣៨៥

E-mail: nssf_ps@nssf.gov.kh

**សាខា ប.ស.ស ខេត្តបាត់ដំបង**

អាសយដ្ឋាន: ផ្ទះលេខP៩ បូរីពាណិជ្ជកម្មបាត់ដំបង ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

ទូរស័ព្ទ: ០៥៣ ៩៥៣ ៣៣៦, ០៩៧ ៩៩៧ ២៨២៩

E-mail: battambang@nssf.gov.kh

**សាខា ប.ស.ស ខេត្តកោះកុង**

អាសយដ្ឋាន: ផ្ទះលេខ២៦ ក្រុម២ ភូមិ៣ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង

ទូរស័ព្ទ: ០៣៥ ៩៣៦ ៤៣៦, ០៩៧ ៩៧៣ ៩០០៦

E-mail: kongkea.nssf.kk@gmail.com

**សាខា ប.ស.ស ខេត្តប៉ៃលិន**

អាសយដ្ឋាន: ភូមិវត្ត សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន

ទូរស័ព្ទ: ០៥៥ ៩៥៦ ៦៦៧, ០៨៦ ៨៩៣ ៧៧៧

E-mail: somit.ream@nssf.gov.kh

**សាខា ប.ស.ស ខេត្តតាកែវ**

អាសយដ្ឋាន: ផ្លូវលេខ១០ ភូមិ២ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ

ទូរស័ព្ទ: ០៣២ ២១០ ៦៦៦, ០១២ ៦៣៦ ៤៣៩

E-mail: soun.vannak@nssf.gov.kh

**សាខា ប.ស.ស ខណ្ឌដង្កោ**

អាសយដ្ឋាន: ផ្ទះលេខ១២A ផ្លូវវេងស្រេង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ (ទល់មុខផែស្ទេតស្វរឆ្វេង)

ទូរស័ព្ទ: ០១២ ៦៩៥ ៥៥០, ០២៣ ៩៩៥ ៤៨៤

E-mail: lpl@nssf.gov.kh

**សាខា ប.ស.ស ខេត្តរតនគិរី**

អាសយដ្ឋាន: ភូមិទេសអន្លង់ សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី

ទូរស័ព្ទ: ០៩៧ ៩៦៦ ៧៦៦៦, ០១១ ៨៥១ ៧៧៧

០៧៥ ៩៧៤ ១៨៤

E-mail: sam_ath@nssf.gov.kh

**សាខា ប.ស.ស ខេត្តមណ្ឌលគិរី**

អាសយដ្ឋាន: ភូមិចំបក់ សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី

ទូរស័ព្ទ: ០១២ ២០៥ ៧៥៦, ០៨៨ ៨២០ ៥៧៥៦

E-mail: kosol_vicheth@yahoo.com

**សាខា ប.ស.ស ខេត្តឧត្តរមានជ័យ**

អាសយដ្ឋាន: ភូមិឈូក សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ

ទូរស័ព្ទ: ០៩៧ ៥២៣ ៤៦៦៦ ០៨៥ ៣១១ ៣០០

E-mail: simao2013@gmial.com

**សាខា ប.ស.ស ខេត្តស្ទឹងត្រែង**

អាសយដ្ឋាន: ភូមិថ្មលាត សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

ទូរស័ព្ទ: ០១២ ៨០៥ ៨៥១

E-mail: nganrathana@gmial.com

**សាខា ប.ស.ស ខេត្តព្រះវិហារ**

អាសយដ្ឋាន: ភូមិកណ្តាល ឃុំកំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ

ទូរស័ព្ទ: ០៩៧ ៣៦៦ ៦០៦០, ០១២ ២៥៩ ២៥៨

E-mail: nssf_pvh@nssf.gov.kh

savuth22@gmail.com

**សាខា ប.ស.ស ខណ្ឌឫស្សីកែវ**

អាសយដ្ឋាន: ផ្ទះលេខ៥០ EoE1 ផ្លូវលេខ៣ ក្រុមទី៤ ភូមិបឹងឈូក សង្កាត់គីឡូម៉ែត្រ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ: ០២៣ ៦៦៣ ៣០៣០, ០៩២ ៨៨៦ ២៥៦

E-mail: vannaknssf@gmial.com

# លេខទូរស័ព្ទទំនាក់ទំនងតាមមន្ទីរពេទ្យដែលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាម៉ុយ | ទូរស័ព្ទទាន់ហេតុការណ៍ | ភ្នាក់ងារ ប.ស.ស | រាជធានី ខេត្ត |
|---|---|---|---|---|---|
| ០១ | មន្ទីរពេទ្យកាលម៉ែត | ១១៩ | ០២៣ ៤២៦ ៩៤៨<br>០២៣ ៧២៤ ៨៩១ | ០៩៧ ៦៨៧ ២៤២៦<br>០៧៧ ៩៧៨ ៤៧៤ | ភ្នំពេញ |
| ០២ | មន្ទីរពេទ្យព្រះកុសុមៈ | ១១៩ | ០១២ ៦៥៧ ៦៥៣<br>០១៦ ៩០៩ ៧៧៤ | ០៩៧ ៦៨៧ ២៤២៩<br>០៩២ ៨២០ ២៥៩<br>០១២ ៦៦៩ ៩៤៦ | |
| ០៣ | មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ១១៩<br>០៧៨ ៩៩៧ ៩៧៨ | ០២៣ ២១៧ ៧៦៤<br>០១២ ៨៥៨ ១៨៤ | ០៩៧ ៦៨៧ ២៤២៧<br>០៩២ ៥៩១ ៣៧៧<br>០១២ ៣០៥ ៣៧១ | |
| ០៤ | មន្ទីរពេទ្យព្រះអង្គឌួង | ០១៦ ៥០៥ ៤៥៣ | ០១១ ៧៥៥ ១១៩<br>០៧៧ ៥៥០ ០១៧ | | |
| ០៥ | មណ្ឌលសុខភាពទួលគោល | ១១៩<br>០១២ ៥១៩ ៩១៦ | ០១១ ៨៣៣ ៣៣៩<br>០២៣ ៣៥១ ១៩៨ | | |
| ០៦ | មន្ទីរពេទ្យបង្អែកសម្ដេចឪ | ១១៩<br>០៧៨ ៣៩៨ ៦៦៧ | ០១២ ៥៣២ ៨០៣<br>០១២ ៨៦៤ ៥០៩ | | |
| ០៧ | មណ្ឌលសុខភាពទឹកថ្លា | ១១៩<br>០៧៧ ៧៩៧ ៩៦៧ | ០១៧ ៧២២ ០៦៥<br>០២៣ ៣៥១ ១៩៨ | | |
| ០៨ | មន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង | ១១៩<br>០១២ ៨៥៣ ០១៣ | ០១៧ ៧២២ ០៦៥<br>០២៣ ៣៥១ ១៩៨ | | |
| ០៩ | មណ្ឌលសុខភាពគោករកា | | ០១៧ ៧៧៥ ៤៧២ | | |
| ១០ | មណ្ឌលសុខភាពស្ទឹងមានជ័យ | | ០១២ ៩៧១ ៤៧៦ | ០៧៧ ៦៣៦ ៣៦០ | |
| ១១ | មន្ទីរពហុព្យាបាល និងសម្ភព សុខ លាភ មេត្រី | ០១១ ៣៩៨ ៨៨៨ | ០២៣ ៦៦៦ ៦២៣៧<br>០១២ ៦០៣ ១៣១ | | |
| ១២ | មន្ទីរសម្រាកព្យាបាលមូលមិត្ត | ០៩៧ ៧៦៣ ៩០០៣ | ០១២ ៤៤៩ ៦០៨ | | |
| ១៣ | មន្ទីរពេទ្យជ័យជំនះ | ០១៥ ៥១៩ ១១៩ | ០១២ ៩១២ ៥២៣<br>០៧៧ ៩៣៣ ៤៥៩ | ០៩៧ ៦៨៧ ២៤២៨ | កណ្ដាល |
| ១៤ | មណ្ឌលសុខភាពបែកចាន | ០១២ ៥៧១ ៦៦៦<br>០១២ ១៧៥ ៨២៨៥<br>០៩៧ ៤៩៩ ៨៩៣៦ | ០១២ ៨៩៤ ២៦០ | ០៩៧ ២៩៩ ៦៦៦៩<br>០៩៦ ៣៦៩ ៥៩១២ | |
| ១៥ | មន្ទីរពេទ្យបង្អែកអង្គស្នួល | ០១២ ៥៨១ ៦៣៩ | ០១២ ៨៩៤ ២៦០<br>០៦៩ ៧០៥ ៧៥៧ | | |
| ១៦ | មន្ទីរពេទ្យបង្អែកកោះធំ | ១១៩<br>០១៧ ៧២២ ០៦៥ | ០២៣ ៣៥១ ១៩៨<br>០១៦ ៤៧១ ៨៨៧ | | |
| ១៧ | មន្ទីរពេទ្យបង្អែកស្រុកស្អាង | ១១៩<br>០១៧ ៧២២ ០៦៥ | ០២៣ ៣៥១ ១៩៨ | | |
| ១៨ | មណ្ឌលសុខភាពព្រែកអញ្ចាញ | | ០១៧ ៥៥២ ៣២៣<br>០១២ ៨៤០ ៥២០ | | |
| ១៩ | មណ្ឌលសុខភាពវិហារសួគ៌ | ០៧៧ ៩២៦ ៦៩២ | ០១២ ៨៣២ ៣៤៣<br>០១២ ៤៩៥ ៩៨៣ | | |
| ២០ | មណ្ឌលសុខភាពសំរោងធំ | ០៩៧ ៧៩៣ ៩៩៧៤ | | | |

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាម៉ុយ | ទូរស័ព្ទទាន់ហេតុការណ៍ | ភ្នាក់ងារ ប.ស.ស | រាជធានីខេត្ត |
|---|---|---|---|---|---|
| ២១ | មន្ទីរពេទ្យបង្អែកប៊ុន រ៉ានី ហ៊ុន សែន រការកោង | ០១៧ ៥៥២ ៣២៣ | ០៩៧ ៩៥៣ ៩៥២៥<br>០១៧ ៥៥២ ៣២៣ | ០៩២ ៤០៧ ៨៦៨ | |
| ២២ | មន្ទីរពេទ្យបង្អែកកំពង់ស្ពឺ | ០១៦ ៦៩៦ ៤៨០ | ០២៥ ៩៨៧ ៣១៣<br>០១៦ ៤៧១ ៨៨៧ | ០៩៧ ៧៨៣ ៩៣៩១ | កំពង់ស្ពឺ |
| ២៣ | មន្ទីរពេទ្យបង្អែកឧដុង្គ | ០៧៨ ៨៩១ ៩១៣<br>០១២ ៩៧៨ ៩២៥ | ០១២ ៩៧៨ ៩២៥<br>០១២ ៩១០ ០៦២ | | |
| ២៤ | មន្ទីរពេទ្យបង្អែកស្វាយរៀង | ០៤៤ ៩៤៥ ១១១ | ០១២ ៩៥៣ ៩៧៥ | ០៩៧ ៧៨៣ ៨៧៦៥ | ស្វាយរៀង |
| ២៥ | មន្ទីរពេទ្យបង្អែកជីភូ | ០១១ ៣៩៤ ១៧៨ | ០១២ ៨០៥ ២៣៦<br>០១២ ៧៦១ ០៨៩ | | |
| ២៦ | មន្ទីរពេទ្យបង្អែកកំពង់ឆ្នាំង | ០២៦ ៩៨៨ ១១១ | ០១៥ ២៥០ ១១១<br>០១២ ៧០២ ២៥១ | | កំពង់ឆ្នាំង |
| ២៧ | មន្ទីរពេទ្យបង្អែកកំពង់ត្រឡាច | ០៨៥ ៥៨៧ ៧៥៧ | ០៨៥ ៥៨៧ ៧៩០<br>០១២ ៤៥៧ ៣០៨ | ០៨៨ ៩៧២ ១០១៦ | |
| ២៨ | មន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ | ០១៦ ៦៨៦ ៨៤៣<br>០៨៨ ៨៦០ ០០៣៩ | ០១២ ៧១២ ៦៤៦<br>០១៦ ៧១២ ៦៤៦ | ០៨៨ ៩៧២ ១០១៤ | ព្រះសីហនុ |
| ២៩ | មន្ទីរពេទ្យ CT (ខេត្តព្រះសីហនុ) | ០៨៩ ៨៨៦ ៦៦៦<br>០៨៥ ៨៨៦ ៦៦៦ | ០៨១ ៨៨៦ ៦៦៦ | | |
| ៣០ | មណ្ឌលសុខភាពវាលរេញ | ០១៦ ៤៥២ ៧៦១ | ០១៦ ២៦៩ ៧៤៤<br>០១២ ៩៨៣ ៦១២ | | |
| ៣១ | មណ្ឌលសុខភាពអណ្ដូងថ្ម | | ០១៥ ៤៥៤ ៥៦២ | | |
| ៣២ | មណ្ឌលសុខភាពរាម | | ០១៦ ៦២៥ ០១១ | | |
| ៣៣ | មន្ទីរពេទ្យបង្អែកសៀមរាប | ០១៦ ៨០០ ១១៩ | ០១២ ៩២៥ ០៦១ | ០៨៨ ៩៧២ ១០១២ | សៀមរាប |
| ៣៤ | មណ្ឌលសុខភាពពួក | ០៨៨ ៨៣៤ ៦២៥៧ | ០៩២ ៩១០ ០២៧ | | |
| ៣៥ | មន្ទីរពេទ្យបង្អែកប៉ោយប៉ែត (អូរជ្រៅ) | ០១២ ៧៨៦ ២៨៦ | ០៨៩ ៨៣៧ ៦៣៧<br>០១២ ៨៣៣ ១៥៩<br>០៩៧ ៧២៦ ៦៤៣០ | ០៨៨ ៩៧២ ១០១៣ | បន្ទាយមានជ័យ |
| ៣៦ | មន្ទីរពេទ្យបង្អែកខេត្តមិត្តភាព កម្ពុជា-ជប៉ុនមង្គលបុរី | ០១២ ៩៣២ ៥២១ | ០១២ ៩២៣ ៣៥៤<br>០៩៧ ៧៤០ ៥៤០១ | | |
| ៣៧ | មន្ទីរពេទ្យបង្អែកសិរីសោភ័ណ | ០១២ ៩១០ ៤៦៧ | ០១២ ៨៥៤ ៩៨៣ | | |
| ៣៨ | មន្ទីរពេទ្យបង្អែកស្រុកជើងព្រៃ | ០១២ ៦៦៧ ៤៨៦<br>០៨៨ ៧៧៤ ៤៧៨៨ | ០៧៧ ៩៩០ ០៤៨ | ០៩៣ ៨៧១ ០៤៣ | កំពង់ចាម |
| ៣៩ | មន្ទីរពេទ្យបង្អែកស្រុកពញាក្រែក | ០៨៨ ៧៧៤ ៤៧១១ | ០៧៧ ៩៩០ ០៤៨ | ០៩៣ ៦៦៩ ៦៣៧<br>០៧៧ ២៦០៤៦៧ | |
| ៤០ | មន្ទីរពេទ្យបង្អែកស្រុកត្បូងឃ្មុំ | ០៨៨ ៧៧៤ ៤៧០០ | ០៧៧ ៩៩០ ០៤៨ | ០៩៧ ៣៨៦ ៨៤២៣ | |
| ៤១ | មន្ទីរពេទ្យបង្អែកស្រុកមេមត់ | ០៨៨ ៧៧៤ ៤៧២២<br>០១២ ៩៦១ ៣៩៣ | ០៧៧ ៩៩០ ០៤៨ | | |

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាម៉ុយ | ទូរស័ព្ទទាន់ហេតុការណ៍ | ភ្នាក់ងារ ប.ស.ស | រាជធានីខេត្ត |
|---|---|---|---|---|---|
| ៤២ | មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម | ០១២ ៨២៣ ៧០៩<br>០៩២ ៩៥៧ ៨៧១ | ០៧៧ ៩៩០ ០៤៨ | ០១៧ ៦២៣ ៧៦៧ | កំពង់ចាម |
| ៤៣ | មន្ទីរពេទ្យបង្អែកព្រៃកក់(ស្ទឹងត្រង់) | ០១២ ៤៩៥ ១៤៨<br>០៩២ ៣២២ ៤១៣ | ០១២ ៤៩៥ ១៤៨<br>០១១ ២៩៤ ៥៣២ | | |
| ៤៤ | មន្ទីរពេទ្យបង្អែកខេត្តក្រចេះ | ០៧២ ២១០ ៣៩១<br>០១២ ៨២២ ៣៩១ | ០១២ ៩៣១ ៨៦៨ | ០៩៧ ៧៩៧ ៨៩៩៩<br>០៩៧ ៩៨៩ ៦៦៩១ | ក្រចេះ |
| ៤៥ | មន្ទីរពេទ្យបង្អែកស្រុកឆ្លូង | ០១២ ៥០២ ៩០៣<br>០១៧ ៩០៩ ៦៥៣ | ០១២ ៣៦៧ ៧០២ | | |
| ៤៦ | មន្ទីរពេទ្យបង្អែកស្រុកស្នួល | ០៩៧ ៧៥២ ៧៩៩៦ | ០៩៧ ៨០០ ៨៥៥៥<br>០៩៧ ៦៥៩ ៧២៩៩ | | |
| ៤៧ | មន្ទីរពេទ្យបង្អែកអ្នកលឿង | ០១២ ៧៧៥ ៣១៩ | ០១២ ៦៦០ ៨១៥ | | ព្រៃវែង |
| ៤៨ | មន្ទីរពេទ្យបង្អែកព្រៃវែង | ០៩៧ ៧៨១ ៦៧៣៥<br>០៨៨ ៨៨០ ០០៧៨ | ០៩៧ ៧៩៥ ៧៤៧២<br>០១៦ ៧១២ ៨០៦ | | |
| ៤៩ | មន្ទីរពេទ្យបង្អែកពារាំង | ០៩២ ៦៥៣ ៥៩៥<br>០១២ ៦៥៣ ៥៩៥ | ០៩២ ២២៣ ៦១៤<br>០៤៣ ៦៩០ ០៩០៥ | | |
| ៥០ | មណ្ឌលសុខភាពក្អឿងរាយ | ០១២ ៦៥៨ ៣០៣ | ០១២ ៤៣៩ ៣៤៣<br>០១២ ២៩៧ ៤៩១ | | |
| ៥១ | មន្ទីរពេទ្យបង្អែកស្រុកចំចាយមារ | ០១២ ៦៩៣ ៩៤០ | ០១២ ៥៨៨ ៤៩៥<br>០៩៥ ៨៨១ ៧០៧ | | |
| ៥២ | មន្ទីរពេទ្យខេត្តតាកែវ | ០១២ ៩៣៥ ៨១៤ | ០១១ ៩០៥ ០១៩<br>០១២ ១៧២ ៨៣៤៨ | | តាកែវ |
| ៥៣ | មន្ទីរពេទ្យបង្អែកបាទី | ០១២ ៧២៤ ០៩៣<br>០៩៧ ៦៤៧ ៤៣០៣ | ០៣២ ៦៩០ ១៩៣៩ | | |
| ៥៤ | មណ្ឌលសុខភាពត្រាំខ្នារ | ០៨១ ៤៤៤ ១៧៤<br>០១២ ៤២៤ ០៦៣ | ០៩៧ ៩៥៩ ៤៦៥៣<br>០១២ ៧២៤ ០៩៣ | ០១២ ៩៤៤ ១៧៤ | |
| ៥៥ | មន្ទីរពេទ្យភ្នែកតាកែវ | | ០១៦ ៩០៤ ៨៩០ | | |
| ៥៦ | មន្ទីរពេទ្យខេត្តកែប | ០១២ ៩១២ ៣២០ | ០១២ ៨២៥ ២៧៧<br>០១២ ៤៥៦ ២៤៧ | | កែប |
| ៥៧ | មន្ទីរពេទ្យបង្អែកខេត្តកំពត | ០១២ ២៩៧ ២៦៨ | ០១២ ៣១៦ ១៣៥<br>០១២ ៩៥៥ ៩៨៦ | | កំពត |
| ៥៨ | មន្ទីរពេទ្យបង្អែកកំពង់ត្រាច | ០១២ ៧៣៣ ៤៦៨ | ០៩២ ៣៨៣ ៦៣២<br>០៨៨ ៨៧៣ ២៤៦៨ | | |
| ៥៩ | មន្ទីរពេទ្យខេត្តពោធិ៍សាត់ | ១៣៥៣<br>/០០១០ | ០១២ ៨២៨ ៤៦៦ | | ពោធិ៍សាត់ |
| ៦០ | មណ្ឌលសុខភាពឈើតុំ | ០៩២ ៣០៧ ២៧៨ | | | |
| ៦១ | មន្ទីរពេទ្យបង្អែកស្រុកក្រគរ | ០៩២ ៨១១ ១៦១ | ០៩៧ ១២២ ២៣៤៤ | | |
| ៦២ | មន្ទីរពេទ្យបង្អែកស្រុកភ្នំក្រវ៉ាញ | ០១២ ៨៥០ ៥៩០ | | | |
| ៦៣ | មន្ទីរពេទ្យបង្អែកស្រែអំបិល | ០១៦ ២២២ ១៨៦ | ០១៦ ៨៧៧ ០០៦ | | កោះកុង |

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាម៉ុយ | ទូរស័ព្ទទាន់ហេតុការណ៍ | ភ្នាក់ងារ ប.ស.ស | រាជធានី ខេត្ត |
|---|---|---|---|---|---|
| ៦៤ | មន្ទីរពេទ្យបង្អែកខេត្តកោះកុង | ០១៦ ៣០០ ១១៩ | ០១៦ ២០៤ ៨៨៧<br>០៩៧ ៧៩៥ ៨៧៨៨ | | កោះកុង |
| ៦៥ | មន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន | | ០៧១ ៩១៤ ៤៤១៨<br>០១៥ ៥៣២ ៣២៣<br>០៩៧ ៧៥៣ ២៣២៣ | | ប៉ៃលិន |
| ៦៦ | មន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង | ០១២ ២៦៩ ៣៨៨ | ០១២ ៨៣៣ ២៦១ | | បាត់ដំបង |
| ៦៧ | មណ្ឌលសុខភាពត្រាង | ០៩៥ ២២៨ ៨៩៣<br>០៩៧ ៩១៤ ៥៨៧០ | ០១៧ ២៦៩ ៣៦៣ | | |
| ៦៨ | មណ្ឌលសុខភាពស្ពៅ | ០១២ ៥៨១ ៦៥៤<br>០៩២ ២៦៤ ១៦៣ | ០១២ ៦៧០ ៩៩៦ | | |
| ៦៩ | មន្ទីរពេទ្យបង្អែកសំពៅលូន | ០១២ ៩៧៤ ២២៣<br>០៨៨ ៩១៨ ១០០៥ | ០១២ ៤៤៨ ១៩៦ | | |
| ៧០ | មន្ទីរពេទ្យបង្អែកថ្មគោល | ០៩២ ៩០៣ ៦៩៤ | ០៩២ ៧៨៦ ៣៥៦ | | |
| ៧១ | មន្ទីរពេទ្យបារាយណ៍-សន្ទុក | ០១២ ៨៦៧ ៥៧៣ | ០១៧ ៥៥៩ ៣៨៧ | | កំពង់ធំ |
| ៧២ | មន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ | ០១៧ ៣៩៨ ៧៥០<br>០១២ ៩៤៧ ៩៣២ | ០៩២ ៩៥៤ ៣៦៧ | | |
| ៧៣ | មន្ទីរពេទ្យបង្អែកស្ទោង | ០១២ ៧៦៨ ៤៤៣<br>០១២ ៧៩៤ ៣៤៩ | ០៩២ ២៩១ ៩៥៩ | | |
| ៧៤ | មន្ទីរពេទ្យបង្អែកខេត្តស្ទឹងត្រែង | ០៩២ ៧៩៩ ៤៦៤<br>០៨៨ ៨៨៤ ៩៤៨៣ | ០៩៧ ៩៧៨ ០៨៧៨<br>០១២ ៩០៨ ៥៩០ | | ស្ទឹងត្រែង |
| ៧៥ | មន្ទីរពេទ្យបង្អែកខេត្តរតនគិរី | ០១៧ ៩៣៦ ៩៤៥<br>០១២ ៨៤០ ៨០៨<br>០១៧ ៣៥៧ ៣២០ | ០១២ ៥០៥ ០០៨<br>០១២ ៥២៨ ០០៨ | | រតនគិរី |
| ៧៦ | មន្ទីរពេទ្យបង្អែកសែនមនោរម្យ | ០៩៧ ៧១២ ១៤៤៥<br>០១២ ៩៦១ ៧៤៤ | ០៩៧ ៤៧៣ ៩៦៨៥<br>០៨៨ ៩៩៨ ៦៥៦៦ | | មណ្ឌលគិរី |
| ៧៧ | មណ្ឌលសុខភាពអូររអាម | ០៩៧ ៤៧៨ ៧៧៩៧ | ០១១ ៦០៧ ៧៨៣<br>០៨៨ ៣៣២ ៩១១៨ | | |
| ៧៨ | មណ្ឌលសុខភាពកែវសីម៉ា | ០៩៧ ៦៧៨ ៨៥៣៣ | ០១២ ២៦៦ ១៥២<br>០៩៧ ៨៥០ ៤៧៦៥ | | |
| ៧៩ | មន្ទីរពេទ្យបង្អែកខេត្តឧត្តរមានជ័យ | ០៩២ ១៤១ ៨៣៥<br>០១២ ៧២៣ ១២១ | ០៧៨ ២២៩ ៧៩៧<br>០៧៨ ៩៧៩ ៧២៩ | | ឧត្តរមានជ័យ |
| ៨០ | មន្ទីរពេទ្យបង្អែកស្រុកអន្លង់វែង | ០៧៦ ៥២៦ ២៤៩១ | ០៧៧ ៥០៨ ០៥៧<br>០១១ ៦៧០ ១៧៤ | | |
| ៨១ | មណ្ឌលសុខភាពអូរស្មាច់ | ០១១ ៧៣៦ ៨៨៦ | | | |
| ៨២ | មន្ទីរពេទ្យបង្អែក ១៦ មករា | ០១២ ៣៧១ ៦១៨ | ០១២ ៤២៦ ៥១៩<br>០១២ ៨៩២ ៩០៩ | | ព្រះវិហារ |
| ៨៣ | មណ្ឌលសុខភាពភ្នំដែក | ០៩២ ២២៧ ៦១៦ | ០៩៧ ៣៩៤ ៤៦៦៩<br>០៩២ ៩៥៦ ៥៦៩ | | |
| ៨៤ | មណ្ឌលសុខភាពជាំក្សាន្ត | | ០១២ ៩៣៨ ១៥៩<br>០៩៧ ៧៥២ ៧៧៧៣ | | |
| ៨៥ | មណ្ឌលសុខភាពស្រអែម | | ០៩៩ ៣៥៨ ៤៤៧ | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION
លេខ ៖ ១០៥ ព.ម/ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៤

# ប្រកាស
## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខន.ស.រ.ក.ម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម/០៨៩៥/០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសារព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០/អ.ន.ក្រ.ប.ក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧១/អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាល និង សោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ របស់ក្រសួងព័ត៌មាន
- បានឃើញប្រកាសរបស់ក្រសួងព័ត៌មានលេខ៦២៥ព.ម.ប្រ.ក ចុះថ្ងៃទី២៧ ខែ តុលា ឆ្នាំ ២០០៩ ស្តីពីការអនុញ្ញាតឲ្យបោះពុម្ពផ្សាយព្រឹត្តិបត្រ " បេឡាជាតិរបបសន្តិសុខសង្គម " ដោយមានលោក ជាវ ប៊ុនរិទ្ធ ជាចាងហ្វាងការផ្សាយ
- យោងលិខិតរបស់លោក ជាវ ប៊ុនរិទ្ធ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣ ស្តីពីសំណើសុំបន្តអាជ្ញាបណ្ណបោះពុម្ពផ្សាយព្រឹត្តិបត្រ " បេឡាជាតិរបបសន្តិសុខសង្គម " ។

## សម្រេច

ប្រការ១ : អនុញ្ញាតឲ្យព្រឹត្តិបត្រ " បេឡាជាតិរបបសន្តិសុខសង្គម " បន្តអាជ្ញាបណ្ណបោះពុម្ពចែកផ្សាយ ដោយមានលោក ជាវ ប៊ុនរិទ្ធ ជាចាងហ្វាងការផ្សាយ ដែលមានទីស្នាក់ការស្ថិតនៅអាគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ២ : រាល់ដំណើរការបោះពុម្ពផ្សាយត្រូវគោរពតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីរបបសារព័ត៌មាន ក្រមសីលធម៌ វិជ្ជាជីវៈអ្នកសារព័ត៌មាន ត្រូវដាក់អាស័យដ្ឋានទីចាត់ការព្រឹត្តិបត្រ ឈ្មោះចាងហ្វាងការផ្សាយ និង ឈ្មោះអាស័យដ្ឋានរោងពុម្ព នៅលើទំព័រព្រឹត្តិបត្ររបស់ខ្លួន ព្រមទាំងយកព្រឹត្តិបត្រ មួយចំនួនមកតម្កល់ទុកនៅនាយកដ្ឋានមណ្ឌលព័ត៌មាន នៃក្រសួង ព័ត៌មាន និងចំនួន ០២ ច្បាប់ តម្កល់ទុកនៅបណ្ណាល័យជាតិ ។

ប្រការ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចចែងក្នុងប្រការ១ និងប្រការ២ ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ៤ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ០១ ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រការ៥ : អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន និងចាងហ្វាងការផ្សាយព្រឹត្តិបត្រ " បេឡាជាតិរបបសន្តិសុខសង្គម " ត្រូវអនុវត្តប្រកាសនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ។/.

រដ្ឋមន្ត្រី

ខៀវ កាញារីទ្ធ

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- គ្រប់សមាគមអ្នកសារព័ត៌មានកម្ពុជា
" ដើម្បីជ្រាបជាព័ត៌មាន "
- សាមីខ្លួន
- ឯកសារ -កាលប្បវត្តិ